មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ ជួប លន់ ភេទប្រុស អាយុ៦២ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ “យោធា”

## ស្រុកកំណើតនៅភូមិគ្រោយ“ង” ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង

## រស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:១៧:១៣

## ២៩ទំព័រ

វណ្ណៈ៖ ចឹងកុំឲ្យខាតពេលយូរ ចឹងថ្ងៃទី២០ខែ១២ឆ្នាំ២០១៣ ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ហើយខ្ញុំមកដល់ភូមិឃុំរបស់ពូក៏ចង់ដឹងរឿងរ៉ាវដែលជាប្រវត្តិសាស្ត្រ ព្រោះថាតាំងពីមុនមកយើងធ្លាប់ឆ្លងកាត់អីខ្លះហើយមកដល់បច្ចុប្បន្ន ហើយមានអ្នកខ្លះនៅខេត្តផ្សេងៗបានមករស់នៅទីនេះ ចឹងបទសម្ភាសខ្ញុំជាពូថ្ងៃនេះពូមិនថាអីទេ?

លន់៖ បាទ ។

វណ្ណៈ៖ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូឈ្មោះអីដែរ?

លន់៖ ជួប លន់ ។

វណ្ណៈ៖ ពូមានឈ្មោះ ហៅ ក្រៅទេ?

លន់៖ អត់មានទេ ។

វណ្ណៈ៖ អាយុប៉ុន្មានហើយ?

លន់៖ អាយុ៦២ ។

វណ្ណៈ៖ ចឹងប្រពន្ធពូឈ្មោះអីដែរ?

លន់៖ ឆាយ សាម៉េត ។

វណ្ណៈ៖ គាត់អាយុប៉ុន្មានដែរ?

លន់៖ អាយុ៥៧ ។

វណ្ណៈ៖ ចឹងពូសព្វថ្ងៃប្រកបមុខរបរអីដែរ?

លន់៖ ធ្វើស្រែចម្ការ ។

វណ្ណៈ៖ ហ្នឹងមានតួនាទីជាមេភូមិ?

លន់៖ បាទ ។

វណ្ណៈ៖ ចឹងពូមានកូនប៉ុន្មាននាក់រាល់ថ្ងៃ?

លន់៖ មាន៨នាក់ ។

វណ្ណៈ៖ ប្រុសប៉ុន្មាន?

លន់៖ មានប្រុស៣ស្រី៥ ។

វណ្ណៈ៖ ចឹងភូមិកំណើតពូនៅណាវិញ?

លន់៖ នៅភូមិត្រោយ«ង» ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ។

វណ្ណៈ៖ ចឹងបើនិយាយពីខាងកើតព្រៃវែងវិញ បើខាង សោ ភឹម បើនិយាយពីជំនាន់បីឆ្នាំគ្រោះថ្នាក់ច្រើនណាស់ ។

លន់៖ បាទ ។

វណ្ណៈ៖ កាលហ្នឹងទាហានគ្រោះថ្នាក់ច្រើន បើនៅមានភាគតិចដែរ?

លន់៖ បាទ ។

វណ្ណៈ៖ ព្រោះអីកាលហ្នឹងខាងនិរតីគេទៅគ្រប់គ្រងវិញ ក្រោយពីចាប់ខ្លួន សោ ភឹម អី ។

លន់៖ បាទ ។

វណ្ណៈ៖ ចឹងសព្វថ្ងៃនេះគេហៅភូមិអីដែរ?

លន់៖ ភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ៖ ចឹងកាលហ្នឹងឪពុកពូគាត់ឈ្មោះអីដែរ?

លន់៖ ឈ្មោះ ឡាយ នុត ។

វណ្ណៈ៖ ម្ដាយ?

លន់៖ ម្ដាយឈ្មោះ ជួប យឹម ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃគាត់ទាំងពីរនៅរស់ដែលឬមួយស្លាប់ហើយ?

លន់៖ ស្លាប់ទាំងពីរ ។

វណ្ណៈ៖ គាត់ស្លាប់ជំនាន់ឥឡូវដែលទេ?

លន់៖ គាត់ស្លាប់តាំងពីមុនឆ្នាំ១៩៧០នោះ ហើយឪពុកខ្ញុំស្លាប់តាំងពីខ្ញុំមិនទាន់ដឹងក្ដី មិនដឹងជាស្លាប់ពេលណាមិនដឹងជាឆ្នាំ៦០ប៉ុន្មាន ។

វណ្ណៈ៖ ចឹងម្ដាយ?

លន់៖ ម្ដាយស្លាប់ខ្ញុំធំដែលហើយ មិនដឹងជាឆ្នាំប៉ុន្មានទេ ។

វណ្ណៈ៖ ចឹងស្លាប់មុនសម័យខ្មែរក្រហមដែរ?

លន់៖ មុនយូរណាស់ ។

វណ្ណៈ៖ ចឹងបងប្អូនពូមានប៉ុន្មាននាក់ដែរ?

លន់៖ មានពីរនាក់ ។

វណ្ណៈ៖ ចឹងមានតែពីរទេ?

លន់៖ បាទ ។

វណ្ណៈ៖ ទី១ឈ្មោះអីទៅ?

លន់៖ ដួប នាថ ។

វណ្ណៈ៖ ចឹងទី២គឺពូ?

លន់៖ បាទ ។

វណ្ណៈ៖ ពូកាលពីតូចបានរៀនសូត្រដល់ថ្នាក់ណាដែរ?

លន់៖ ខ្ញុំបានដល់ថ្នាក់ទី១០ចាស់ ។

វណ្ណៈ៖ កាលហ្នឹងរៀននៅសាលាបឋមសិក្សាណា?

លន់៖ សាលាបឋមសិក្សាគោកសណ្តែក ។

វណ្ណៈ៖ យ៉ាងម៉េចបានទៅបានពូឈប់រៀនត្រឹមថ្នាក់ទី១០ "ចាស់" ដោយសារមូលហេតុអី?

លន់៖ កាលហ្នឹងនៅក្នុងគ្រួសារពិបាក មានតែពីរនាក់បងប្អូន ហើយវាកំព្រាម៉ែឪហើយឈប់ជួយធ្វើការបងប្អូនទៅដល់ក្រោយមកស្រុកកើតសង្គ្រាមនៅឆ្នាំ១៩៧០ ។

វណ្ណៈ៖ ចឹងមានន័យថាពូឈប់រៀនមុនរដ្ឋប្រហារឆ្នាំ១៩៧០ទៀត?

លន់៖ ឈប់មុនប្រហែលជាពីរឆ្នាំ ចឹងហើយប្រហែលជាពីរឆ្នាំដល់រដ្ឋប្រហារ ។

វណ្ណៈ៖ ចឹងនៅពេលកើតរដ្ឋប្រហារឆ្នាំ១៩៧០ពូនៅផ្ទះដែលឬមួយគេមកឃោសនាឲ្យចូលចលនាអីឬនៅ?

លន់៖ កាលឆ្នាំ១៩៧០ហ្នឹងខ្ញុំនៅផ្ទះ ។

វណ្ណៈ៖ ចឹងនៅឆ្នាំណាបានពូចូលចលនារំដោះជាតិកាលហ្នឹង?

លន់៖ ចាំមើលកាលនេះនៅមូលដ្ឋានហ្នឹងនៅឆ្នាំ១៩៧១ ខ្ញុំធ្វើឈ្លបឃុំកាលហ្នឹង ។

វណ្ណៈ៖ ចឹងកាលពូចូលជាឈ្លបឃុំនៅឆ្នាំ១៩៧១ហ្នឹងពូចូលដោយស្ម័គ្រចិត្តឬមួយយ៉ាងម៉េច?

លន់៖ កាលគេចលនាស្ម័គ្រចិត្តការពារភូមិឃុំហ្នឹងណាស់ ហើយក្រោយមកខ្ញុំឈប់ឈ្លបហ្នឹងមកនៅភូមិវិញធ្វើគ្រូអក្ខរកម្មបង្រៀនព្រោះកាលហ្នឹងយន្តហោះទម្លាក់ ខ្វះគ្រូបង្រៀនណាស់ យន្តទម្លាក់នៅផ្សាររក្សជ័យហ្នឹង អត់មានគ្រូបង្រៀន អត់មានគ្រូបង្រៀនខ្ញុំឈប់ទៅធ្វើគ្រូតាមភូមិបង្រៀនតាមភូមិ បង្រៀនក្មេងនិងមនុស្សចាស់ដែលយើងខ្ញុំបានចេះបន្តិចបន្តួចហ្នឹងណាស់រៀនបន្ត ដើម្បីឲ្យកូននៅក្នុងស្រុកភូមិបានចេះ ។

វណ្ណៈ៖ បាទ ។

លន់៖ ធ្វើគ្រូរហូតចឹង ដល់ផុតពីហ្នឹងដល់ឆ្នាំ១៩៧២ ខ្ញុំចេញទៅធ្វើកងទ័ព ។

វណ្ណៈ៖ ចឹងកាលដែលពូធ្វើឈ្លបហ្នឹងយើងការពារយ៉ាងម៉េចហ្នឹង?

លន់៖ ការពារត្រឹមឃុំយើងទេ ឧទាហរណ៍ឃុំទំនប់ដាច់ចឹងណាស់ ព្រំប្រទល់ត្រឹមណាការពារតែឃុំទេកាលហ្នឹង ។

វណ្ណៈ៖ កុំឲ្យខ្មាំងចូលឬយ៉ាងម៉េច.?

លន់៖ អាហ្នឹងយើងខ្លាំមើលខ្មាំងចុះយើងឈ្លបមានតួនាទីអីវាយទេ គ្រាន់តែការពារប្រជាជនមើលខ្មាំងវាយចូលមកស្រុកភូមិអី គ្រាន់ឲ្យប្រជាជនដឹងដើម្បីយើងភាសខ្លួនអីហ្នឹងណាស់ ជំនាន់ហ្នឹងនោះ ។

វណ្ណៈ៖ ចឹងកាលហ្នឹងសង្គ្រាមចាប់មានវាយជាមួយទាហាន លន់ នល់ ហើយ?

លន់៖ មានហើយ ។

វណ្ណៈ៖ ចឹងកន្លែងពូរស់នៅហ្នឹងភាគច្រើនចូលទៅជីរំដោះហើយឬយ៉ាងម៉េច?

លន់៖ នៅជីរំដោះនៅការពាររបស់របរ គោ ក្របី ជ្រូក មាន់ ទា មិនឲ្យចេញទៅតំបន់ខ្មាំងពួកខ្ញុំនៅរក្សជ័យហ្នឹងមានទន្លេវ័ណ្ឌ ព្រោះទន្លេកាណូតបើកបរមកអ្នកលឿង កំពង់សឹង អ្នកលឿងហើយនិងពាមជួចនេះវ័ណ្ឌទន្លេហ្នឹង តែដូចជាឈើកាចអី ទាហាន លន់ នល់ ចូលដល់គេមកពាតត្បាតដល់ចឹងវាផ្លាស់ចូលមកខាងជីរំដោះហ្នឹង ។

វណ្ណៈ៖ ចឹងរុញទៅរុញមក?

លន់៖ រុញទៅរុញមកហ្នឹងហើយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានការឃោសនាឲ្យកូនចៅចូលព្រៃម៉ាគីដែរ ពូដឹងទេពេលហ្នឹង?

លន់៖ មានដឹង កាលហ្នឹងសម្តេចសីហនុហ្នឹង លោកអំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីតស៊ូយកប្រទេសជាតិទឹកដីមកវិញ ព្រោះកាលហ្នឹងលោក លន់ នល់ ធ្វើរដ្ឋប្រហារសម្តេចហ្នឹងណាស់កាលហ្នឹង ។

វណ្ណៈ៖ បាទ ។

លន់៖ ដណ្តើមរាជ្យបល័ង្កហ្នឹង ហើយសម្តេចកាលហ្នឹងយើងបើកតែប៉ុស្តិ៍ចិនទេ ព្រោះមិនមានប៉ុស្តិ៍អីទេ ប៉ុស្តិ៍ចិនអំពាវនាវកូនចៅអើយចូលព្រៃម៉ាគីទៅតស៊ូដើម្បីប្រទេសជាតិទឹកដី ចឹងណាស់ហើយកូនចៅធ្វើតាមសម្តេចហ្នឹង មិនខុសពីសម្តេចទេខាងខ្ញុំនោះកន្លែងហ្នឹងគេហៅតំបន់២៤ណាស់ ។

វណ្ណៈ៖ បាទ!ចឹងនៅហ្នឹងតំបន់២៤?

លន់៖ បាទ! តំបន់២៨ ។

វណ្ណៈ៖ ភូមិភាគអីកាលហ្នឹង?

លន់៖ ភូមិភាគបូព៌ា ។

វណ្ណៈ៖ ចឹងគណៈតំបន់ពេលហ្នឹងពូមានស្គាល់ទេ?

លន់៖ គណៈតំបន់តាយួន ។

វណ្ណៈ៖ ចឹងឈ្មោះតាយួន?

លន់៖ បាទ! មិនដឹងជាស្អីយួនទេ គាត់ឈ្មោះយួនចឹងឯង ។

វណ្ណៈ៖ ចឹងគណៈភូមិភាគ?

លន់៖ ភូមិភាគមិនស្គាល់ ។

វណ្ណៈ៖ មិនមែនតាសោ ភឹម ទេកាលហ្នឹង?

លន់៖ មិនមែនទេ សោ ភឹម នៅព្រៃវែង សោ ភឹម ខាងកងទ័ព ។

វណ្ណៈ៖ តែក្រោយមកតា សោ ភឹម គាត់កាន់ខាងភូមិភាគបូព៌ាទាំងអស់ខាងព្រៃវែង?

លន់៖ បាទ! តែឈ្នះហើយទេ ។

វណ្ណៈ៖ ចឹងមិនមែនកាន់តាំងពីសម័យតស៊ូទេ?

លន់៖ កាលសម័យតស៊ូមិនដែលឮដងហ្នឹង ខ្ញុំដឹងតែតាយួន ។

វណ្ណៈ៖ ចឹងតាយួនហ្នឹងគាត់ជាគណៈតំបន់ ។

លន់៖ គណៈតំបន់ ។

វណ្ណៈ៖ ចឹងគណៈភូមិភាគពូមិនបានស្គាល់ទេកាលហ្នឹង?

លន់៖ អត់ស្គាល់គេផង ។

វណ្ណៈ៖ ចឹងកាលពីចូលជាយោធា១៩៧២ហ្នឹង ជាយោធាស្រុកឬជាយោធាចូលសមរភូមិតែម្តង?

លន់៖ ចូលខាងយោធាតំបន់កាលហ្នឹងខ្ញុំនៅខាងភស្តុភាខាងដឹកជញ្ជូន នៅជាមួយតាយួនហ្នឹងឯងនៅជាមួយគណៈតំបន់ហ្នឹងតែខាងដឹកជញ្ជូន កាលហ្នឹងកងដឹកជញ្ជូនខាងដើងទឹកកាណូត កាលហ្នឹងមានតែកាណូតទេ ខ្ញុំនាំស្បៀងចេញចូលចឹងណាស់ ឲ្យកងទ័ពហូប ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមិនបានឡើងវាយទេ?

លន់៖ មិនទាន់បានវាយទេ ដំនាន់ហ្នឹង ខ្ញុំទៅអ្នកលឿងបានដឹកអ្នករបួសដឹកសពហ្នឹងអ្នកពលីដឹកជញ្ជូនទ័ពអីហ្នឹង ខ្ញុំនៅខាងភស្តុភា ។

វណ្ណៈ៖ ចឹងកាលសង្គ្រាម៥ឆ្នាំហ្នឹងពូគិតថាធ្វើឲ្យទាហាន លន់ នល់ ជាខ្មែរដែរ ទាំងទាហានខ្មែរក្រហមក៏ជាខ្មែរដែរ តើពេលធ្វើសង្គ្រាមហ្នឹងមានស្លាប់មានរបួសច្រើនទេក្នុងពេលហ្នឹង?

លន់៖ ខ្ញុំដឹកខ្លួនខ្ញុំច្រើនណាស់ ព្រោះសមរភូមិអ្នកលឿនខ្ញុំដឹកសមរភូមិអ្នកលឿនហ្នឹងបើអ្នកពលីកប់នៅវត្តវាលដំបងបើអ្នកនៅរស់ដឹកមកមើលរហូតដល់មន្ទីរពេទ្យ ។

វណ្ណៈ៖ ចឹងមានអ្នកស្លាប់យើងមិនបានបញ្ជូនទៅដល់ម៉ែឪវិញទេ?

លន់៖ អត់ទេ បញ្ជូនទៅណាគេមានកន្លែងគេដាក់ដូចថាអ្នកលឿនចឹងមកកប់នៅវាលដំបង ជួនកាលកប់នៅវត្តតាំងចារចឹងទៅកប់នៅហ្នឹង ដល់ញឹកពេករណ្តៅដឹកមិនទាន់អ្នកស្លាប់ច្រើនចឹងមួយរណ្តៅពីរទៅបីនាក់ហើយដាក់តែឈ្មោះទៅដល់ឪពុកម្តាយមករកមើលតាមឈ្មោះហ្នឹង ដល់ចប់សង្គ្រាម ។

វណ្ណៈ៖ ចឹងមានកត់ឈ្មោះដែរ?

លន់៖ កត់ឈ្មោះដាក់ផ្លាកឧទាហរណ៍ឈ្មោះ "ក-ខ" ចឹងទៅ ។

វណ្ណៈ៖ បាទ ។

លន់៖ ហ្នឹងហើយដាក់ស្តែងខ្ញុំអ្នកដឹកមនុស្សស្លាប់ ។

វណ្ណៈ៖ យើងដឹកឡានឬយកអីដឹក?

លន់៖ ដឹកកាណូត តាមអាងកុកហ្នឹង អាងកុកហ្នឹងដឹកចេញមកវាលដំបងបើអ្នកណាស្លាប់កប់នៅវាលដំបងអ្នកណានៅរស់យកទៅអគ្គរអង់ពេទ្យចល័តគេហ្នឹង ចេញពីពេទ្យចល័តបានមកពេទ្យប្រចាំនៅតាំងចារចឹងទៅណាស់ ។

វណ្ណៈ៖ បាទ!ចឹងកាលឆ្នាំ១៩៧២ហ្នឹងខាងខ្មែរក្រហមមានសហការជាមួយខាងវៀតណាមទេ ព្រោះកាលហ្នឹងយើងមានពឹងវៀតណាមដែលនៅកន្លែងខ្លះ ពឹងវៀតណាមឲ្យជួយខាងខ្មែរក្រហមខាងលន់ នល់ ពឹងវៀតណាមដែលតែខាងធៀវគឺ កាលហ្នឹងមានពីរបក្ស ចឹងកាលហ្នឹងខាងពូមានពឹងកម្លាំងខាងវៀតណាមដែលឬមួយអត់ទេ?

លន់៖ អត់ទេ ចេះកាលខ្ញុំចូលហ្នឹងផុតហើយ កាលហ្នឹងមានយួនមែន កាលមុនខ្ញុំហ្នឹងមានជំនាន់បងខ្ញុំដែលធ្វើមុនពីរបីឆ្នាំហ្នឹង ។

វណ្ណៈ៖ ចឹងបងពូចូលបដិវត្តដែរ?

លន់៖ អត់ទេ បងស្រីខ្ញុំអត់ទេ ដូចថាបងៗខ្ញុំដូចថាអាយុបងខ្ញុំហ្នឹងចឹងណាស់ កាលពីបងៗខ្ញុំហ្នឹងធ្វើគ្រូអីចឹងណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ ដូចជាគ្រូ អុល ដូចជាគ្រូ ញាញ់ អីជាមួយគ្រូ អៀប អីហ្នឹងណាស់ មានតែយួនវៀតមិញខ្មៅទេ ដែលមានសហការជាមួយដំបូង ។

វណ្ណៈ៖ បាទ ។

លន់: ហ្នឹងហើយ ។

វណ្ណៈ: ដល់ឆ្នាំណាអស់ទៅវិញ?

លន់: ឆ្នាំ១៩៧៥អត់ដឹងថាទៅណាទេ អស់អាហ្នឹងដល់ឈ្នះចឹងទៅមិនដឹងជាទៅណាទេ ហើយជំនាន់នោះអ្នកដែលធ្វើសង្គ្រាមនោះអ្នកស្លាប់អស់ច្រើនចាស់ៗហ្នឹង នៅមួយៗពួកខ្ញុំចូលទៅតាមក្រោយទៀត ។

វណ្ណៈ: បាទ ។

លន់: ចឹងណាស់ មានជំនាន់ណាស់ ។

វណ្ណៈ: ចឹងពេលពូបានចូលទៅសមរភូមិពូមានការភ័យខ្លាចដែលទេកាលហ្នឹង?

លន់: កាលខ្ញុំហ្នឹងមួយវគ្គ៧៥ហ្នឹងខ្ញុំមិនបានវាយទេ ខ្ញុំបានតែដឹកជញ្ជូនទេ ផ្នែកខាងសេដ្ឋកិច្ចខាងភស្តុភាណាស់ ។

វណ្ណៈ: បាទ ។

លន់: ដល់ចប់ហ្នឹងហើយអាហ្នឹងបានខ្ញុំបានវាយ ពួកខ្ញុំទៅខាងកងទ័ពវិញអាហ្នឹងចប់៧៥ណាស់ ។

វណ្ណៈ: បាទ!ឥឡូវខ្ញុំចង់សួរចន្លោះពី៧៤-៧៥ដែលវាយចូលភ្នំពេញហ្នឹង តើខាងកម្លាំងភូមិភាគបូព៌ាហ្នឹង បានវាយចូលដល់ភ្នំពេញដែលឬមិនបានវាយចូលទេ?

លន់: ខាងភូមិភាគបូព៌ាហ្នឹងខាងកងទ័ពអត់បានវាយទេ វាយបានត្រឹមអ្នកលឿងហើយនិងព្រៃវែង វាយត្រឹមអ្នកលឿងនិងព្រៃវែង ។

វណ្ណៈ: ចឹងមានន័យថា ទ័ពបូព៌ាវាយត្រឹមអ្នកលឿង?

លន់: បាទ!អ្នកលឿងនិងព្រៃវែងអានេះតាមដឹងណាស់ ព្រោះមានកងទ័ពតំបន់និងកងទ័ពមជ្ឈិមគេហៅកងទ័ពមជ្ឈិមណាស់នៅរួមវាយ ។

វណ្ណៈ: ចឹងកាលនៅឆ្នាំ១៩៧៤ហ្នឹងពូមានដឹងថា ពូនៅក្នុងកងពលណាទេ?

លន់: ៧៤យើងវាយនៅហ្នឹង ។

វណ្ណៈ: តែមានកងពលនៅកាលហ្នឹង ប្រធានកងពលអី?

លន់: ប្រធានកងពលអត់ដឹងទេ មានតែវរសេនាធំ ។

វណ្ណៈ: ចឹងពូនៅក្នុងវរសេនាធំលេខប៉ុន្មានដែរ?

លន់: កាលហ្នឹងខ្ញុំនៅខាងភស្តុភាខាងតំបន់ ។

វណ្ណៈ: ចឹងពូនៅតំបន់?

លន់: បាទ!ខ្ញុំនៅតំបន់ ។

វណ្ណៈ: ចឹងតំបន់ហ្នឹងអត់មានកងវរៈស្សឹទេឬកងវរសេនាតូចវរសេនាធំអីទេ?

លន់៖ វាមានកងដឹកជញ្ជូនខ្ញុំនៅកងដឹកជញ្ជូនទេ តែកងទ័ពតំបន់នោះវាមានកងវរសេនាតូចកងវរសេនាធំ ។

វណ្ណៈ៖ ចឹងកងដឹកជញ្ជូនហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

លន់៖ តែខាងខ្ញុំហ្នឹងមានតែ១២នាក់ទេ ខាងទូកខាងអង្ករសំភារៈអីហ្នឹងណាស់ ខ្ញុំដឹងថាខាងហ្នឹងខាងគ្រាប់អីហ្នឹងណាស់ ។

វណ្ណៈ៖ ចឹងគ្រាប់កាលហ្នឹងយើងមានបានដឹងថាមកពីខាងណាទេ?

លន់៖ ឃើញគេដឹកចេញពីសេនាធិការមកដាក់កាណូតមកឲ្យខ្ញុំហើយយើងដឹកតទៅទៀតហើយចឹងទៅកងនារីយកមកហ្នឹងចាំគ្រាប់ចឹងទៅហើយទៅស្នើមេកងនារីឲ្យគេដឹកជញ្ជូនចូលមក កាលហ្នឹងយើងដឹកតាមទន្លេតូចអីហ្នឹង ទន្លេអ្នកលឿងអីហ្នឹង និយាយរួមកងទ័ពយើងនៅតាមដងទន្លេប្រយកមកទុកកន្លែងចឹង កងទ័ពមកយកខ្លួនគេយើងមិនអាចចូលបានទេនៅហ្នឹង ព្រោះយើងអត់ដឹងកន្លែងណាគេនៅទេ ។

វណ្ណៈ៖ បាទ ។

លន់៖ ហ្នឹងហើយជំនាន់ហ្នឹងខ្ញុំដឹងចឹង អ្នកលឿងហ្នឹងវាយយួរណាស់ វាយរហូតដល់ផ្តាច់ព្រាត់ងាប់មិនថាអ្នកណាខ្មែរ ចិន យួន អ្នកលឿងហ្នឹងងាប់ច្រើន ដូចថាកងទ័ពមួយវរៈហ្នឹង ឧទាហរណ៍ថាថ្ងៃហ្នឹងអស់៥០ហ្នឹង ស្អែកចូល៥០ទៀត១០០ទៀតចឹង កាលរំកិលឡើងវាយទាល់ឈ្នះកាលហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងងាប់៥០នាក់ចូល៥០នាក់?

លន់៖ ងាប់៥០នាក់ចូល១០០នាក់ក៏មានដែរ អាខ្មែរត្រៀមដាក់ត្រៀមឡើងវាយរហូតបាយស្បៀងចេះតែយកទៅចឹង ហើយខាងខ្ញុំចេះតែដឹកទៅហើយកងទ័ពគេយកទៅចែកគ្នាទៅហ្នឹងចឹង ។

វណ្ណៈ៖ ចឹងពូមានដឹងថាមានមូលហេតុអីបានជាខាងចលនាខ្មែរក្រហមហ្នឹងវាយខាងទាហានលន់ នល់ហ្នឹងបានលឿនរហូតដល់បានទទួលជ័យជំនះដូចជាមិនយូរអីប៉ុន្មានសង្គ្រាម៥ឆ្នាំឈ្នះ?

លន់៖ អាហ្នឹងយើងជឿដាក់តាមសម្តេចឪ ព្រោះអំពាវនាវឲ្យចូលព្រៃម៉ាគី បើយើងមិនវាយស្លាប់បើយើងវាយរស់និយាយចឹង តែមិនមានច្បាប់អីតឹងរឹងថា យ៉ាងណាយ៉ាងណីនោះទេមនុស្សបាក់ទៅតាមគ្នា ទោះបីទាំងក្មួយទាំងខ្ញុំ ទោះបីខ្ញុំមានប្រពន្ធកូនមួយហើយក៏ខ្ញុំទៅដែរ នណាមានកូនប៉ុន្មានក៏ទៅដែរ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានប្រពន្ធហើយ?

លន់៖ បាទ!មានប្រពន្ធកូនមួយហើយបានខ្ញុំចេញ ។

វណ្ណៈ៖ ចឹងពូរៀបការតាំងពីសម័យមុនបីឆ្នាំទៀត?

លន់៖ អត់ទេ មុនៗអាហ្នឹងបីឆ្នាំយើងចប់សង្គ្រាមហើយទេ អានេះយើងនិយាយឆ្នាំ១៩៧៥ អាបីឆ្នាំផ្សេងៗ

វណ្ណៈ៖ ចឹងពូការមុន?

លន់៖ មុនសង្គមទម្លាក់គ្រាប់បែកនោះៗ

វណ្ណៈ៖ តាំងពី៧២-៧៣?

លន់៖ នៅលោកៗ

វណ្ណៈ៖ ចឹងពូបួសលោកទៀត?

លន់៖ អត់ទេ នៅមានលោកសង្ឃដើរមុនអីណាស់ ដល់ក្រោយមកយើងសឹកលោកអស់ហើយ ហ្នឹងកាលហ្នឹងនៅមានលោក ហើយទម្លាក់គ្រាប់បែកភូមិស្រុកអីហ្នឹង ថាភូមិខ្ញុំគ្រាំគ្រាជាងគេទម្លាក់នៅវត្តជ័យហ្នឹងគ្រាំគ្រាណាស់ គ្រាប់ផ្ទោងជូនណាយាយៗមកពីវត្តមក ដូចជាយាយ ឡាអី គាត់មកដល់មុនក្លោងទ្វារវត្តទ្រុងខ្លាហ្នឹង គាត់មកដល់ត្រង់ហ្នឹងគ្រាប់ធ្លាក់មកចំគាត់ដាច់គាត់ក្បាល ចឹងតើជំនាន់ហ្នឹងៗ

វណ្ណៈ៖ បាទៗ

លន់៖ វាពិបាកណាស់ៗ

វណ្ណៈ៖ ចឹងពេលឆ្នាំ១៩៧៥ពេលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញទាំងអស់ ចឹងខាងបូព៌ាអត់បានចូលទេ ចឹងមានបានដឹងដំណឹងថា កងពលណាខ្លះដែលបានចូលដល់ទីក្រុងភ្នំពេញមុនអីចឹង?

លន់៖ ចេះកាលព្រៃវែងហ្នឹងខ្ញុំបានដឹងថា ទាហាន លន់ នល់ លើកទង់សមិនបានវាយទេ ហ្នឹងគេចុះចូលមកណាស់ ហើយខាងអ្នកលឿងវាយ វាយទាល់តែខ្ទិចតែម្ដងមិនបានចុះចូលទេៗ

វណ្ណៈ៖ បាទៗ

លន់៖ ហ្នឹងខ្ញុំដឹងថា កងទ័ពស្រីខាងតំបន់២៥ណាស់ ហែលទឹកចុះពីកំពង់ភ្នំមកៗ

វណ្ណៈ៖ កំពង់ភ្នំ?

លន់៖ បាទ!ចុះបណ្ដែតមកចូលដល់អ្នកលឿងហ្នឹង អាហ្នឹងកងពលសាឡាងហ្នឹងឡើងវាយនៅហ្នឹងបានឈ្នះ ហើយបើត្រង់សេមួយសុទ្ធតែទាហាននៅអ្នកលឿងហ្នឹងហើយដល់ក្រោយមក៧៥នេះខ្ញុំបានឡើងទៅបើកកាណូតទៅយកសម្ភារៈនៅវាំមឹកងទ័ពគេវាយបានហ្នឹង ខ្ញុំក៏ទៅលេងត្រឹមអ្នកលឿងទៅ ឃើញប្រជាជនគេរំដោះចេញពីភ្នំពេញមកៗ

វណ្ណៈ៖ ចឹងពូគ្រាន់តែឃើញទេ?

លន់៖ បាទ!គ្រាន់តែឃើញមកៗ

វណ្ណៈ៖ ចឹងពូអត់ទាន់ចូលភ្នំពេញទេចឹង?

លន់៖ អត់ទាន់ចូលទេ អាហ្នឹងខាងខ្ញុំណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ តែខ្ញុំដឹងកងទ័ព តែមិនសូវដឹងថាកងទ័ពណាខ្លះខ្ញុំមិនសូវដឹងទេខ្ញុំ ព្រោះយើងនៅតូចតាច ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមិនទាន់មានឋានៈអីទេ?

លន់៖ អត់មានទេ ខ្ញុំមានឋានៈអីខ្ញុំគ្រាន់ជាអ្នកដឹកជញ្ជូនខ្ញុំអ្នកបើកកាណូត កាណូតធំៗមិនមែនតូចៗទេ ធំជាងផ្ទះនេះទៀត ។

វណ្ណៈ៖ ចឹងកាណូតធំៗចឹង?

លន់៖ បាទ!សុទ្ធតែអាគូទង យើងឡានដឹកចេញមួយអាទិត្យមិនទាន់អស់ទេ ត្រឹមឡានមួយឡានពីរ ។

វណ្ណៈ៖ ទូកមួយហ្នឹង?

លន់៖ ទូកមួយ តែឡានពីដើមតូចៗ ។

វណ្ណៈ៖ ចឹងពេលបែកភ្នំពេញហើយរយៈពេលប៉ុន្មានបានពូចូលដល់ភ្នំពេញឬមួយពូអត់បានចូលទេ?

លន់៖ អត់ទេ អត់ដែលស្គាល់ទេ ។

វណ្ណៈ៖ ចឹងគេបញ្ជូនពូឲ្យទៅខាងណាវិញទៅ?

លន់៖ ខ្ញុំទៅខាងព្រំដែន ។

វណ្ណៈ៖ ព្រំដែនខាងណា?

លន់៖ ព្រំដែនខាងយួន អាហ្នឹងគេហៅស្រុកព្រះស្ដេច ខាងស្រុកត្របែកអាហ្នឹងនៅព្រំប្រទល់ខាងខេត្តស្វាយរៀងណាស់ ។

វណ្ណៈ៖ តែនៅជាយដែនមិនមែននៅកណ្ដាលក្រុងទេ?

លន់៖ នៅជាយដែន ។

វណ្ណៈ៖ ចឹងពូទៅការពារជំបូងនៅព្រំដែនខ្មែរ-យួន តើយើងនៅមានទំនាក់ទំនងគ្នាបានដែលឬទៅដល់យើងបាញ់គ្នាតែម្ដងឬអត់មានទេជំបូងៗហ្នឹង?

លន់៖ អត់ទេ កាលឆ្នាំ១៩៧៥ខ្ញុំទៅនៅចូលអង្គភាពគេហ្នឹង ខ្ញុំនៅអង្គភាព“យ” ។

វណ្ណៈ៖ ចឹងនៅក្នុងកងពលប៉ុន្មានដែលនៅឆ្នាំ១៩៧៥ គេមានកងពលច្បាស់លាស់ហើយ?

លន់៖ នៅ កាលហ្នឹងគេដាក់“យ៨” ហៅ“យ៨”ខ្ញុំនៅចំណុះ“យ៨”ណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ មានគ្នាតែ៣០នាក់ទេ នៅខាងកាំភ្លើងធំ ។

វណ្ណៈ៖ ចឹងពេលហ្នឹងពូមានស្គាល់តាសោ ភឹម អីទៅ?

លន់៖ មិនស្គាល់ទេ អត់ស្គាល់ សោ ភឹម និយាយរួមមិនស្គាល់គេទេ គ្រាន់តែឮៗសោ ភឹម ប្រចាំការនៅព្រៃវែង ខ្ញុំគ្រាន់តែឮ។

វណ្ណៈ៖ ចឹងនៅខាងអង្គភាព“យ៨” ហ្នឹងពីណាប្រធានទៅ?

លន់៖ កាលហ្នឹងបងសារ៉ែន។

វណ្ណៈ៖ ចឹងសារ៉ែន មិនមែនប្រធានកងពលទេ?

លន់៖ ប្រធាន“យ” ហ្នឹងខាងលេខា។

វណ្ណៈ៖ ចឹងពូនៅមួយអង្គភាពហ្នឹងមានគ្នាតែ៣០នាក់ទេ?

លន់៖ ទេ អាហ្នឹងខ្ញុំនៅចំណុះ“យ” មានគ្នា៣០នាក់។

វណ្ណៈ៖ ចឹងបើសរុបទាំងអស់?

លន់៖ អាហ្នឹងចេះ ដូចថាកាំភ្លើងធំមានគ្នា១០នាក់ ដួនកាលមាន២០នាក់នៅខាង“យ” ហ្នឹងហើយខ្ញុំនៅខាងកាំភ្លើងធំ អាហ្នឹងគេហៅកងគាំទ្រ“យ” ។

វណ្ណៈ៖ បាទ។

លន់៖ ហ្នឹងហើយមើលការខុសត្រូវត្រួតពិនិត្យលើតាម“គ” ហ្នឹងមានបី“គ” ហ្នឹងអាហ្នឹងចឹង ហើយ“យ” មានបីបួននាក់។

វណ្ណៈ៖ ចឹងកាលពូនៅកងទ័ព ពូមានដឹងថានៅខាងក្រោយប្រជាជនមានការហូបចុកយ៉ាងម៉េចពូមានដឹងទេ កាលហ្នឹង នៅខាងសហករណ៍អីកាលហ្នឹង?

លន់៖ សហករណ៍ដឹង ព្រោះកាលនៅខាងស្រុកគេហ្នឹងគឺគេធ្វើសហករណ៍ដែរ អាហ្នឹងមុនដំបូងយើងហូបបាយរួមហ្នឹង គេឲ្យចូលហូបបាយរួមហ្នឹងយើងមានគោមានមាន់កាប់ហូបចឹង គេមិនមានហូបឯកជនទេ មុនដំបូងបង្អស់គេឲ្យយើងហូបតាមគ្រួសារចឹងខ្វះ កាលហ្នឹងមានចែកស្រូវអង្ករដល់ក្រោយមកគេឲ្យហូបជារួម ថាផ្ទះខ្ញុំចឹងមានជ្រូកមានមាន់ហ្នឹងគេមកយកទៅធ្វើបាយរួមទៅឲ្យគេទៅ មានគោមានអីចឹង មានគោគេដាក់ម្ដុំ។

វណ្ណៈ៖ បាទ។

លន់៖ មាន់កាលហ្នឹងសម្បូរគេឲ្យចិញ្ចឹមតាមផ្ទះយកតាមផ្ទះណាស់ ដល់ក្រោយៗមកហ្នឹងគេចិញ្ចឹមមួយកន្លែងរួម។

វណ្ណៈ៖ បាទ។

លន់៖ អ្នកធ្វើការក៏ធ្វើការរួមដែរ កូនចៅអីនរណាទៅកងចល័តកងចល័តទៅអ្នកណារៀនៗចឹងទៅ អាហ្នឹងចឹងដល់ពេលម៉ោងហូបបាយវាយជួង។

វណ្ណៈ៖ ចឹងកាលដែលឈ្នះភ្នំពេញ ពូមានបានទៅលេងស្រុកកំណើតជួបប្រពន្ធកូនវិញបានដែលអត់កាលហ្នឹង?

លន់៖ ខ្ញុំបានទៅហ្នឹងជិតបែកហើយ ព្រោះកាលដែលបែកភ្នំពេញអីអស់ខ្ញុំអត់បានទៅគេបញ្ជូនខ្ញុំទៅព្រំដែន ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូអត់មានសុំគេទៅលេងផ្ទះទេ?

លន់៖ អត់ទេ វាចេះវាពិបាកសុំ គេមិនឲ្យចេញទៅណា ព្រោះយើងនៅក្នុងកងដឹកជញ្ជូននៅតំបន់២៨ហ្នឹង នៅជាមួយគណៈតំបន់ហ្នឹងដល់ពេលហ្នឹងគណៈតំបន់ហ្នឹងនៅពេលចប់សង្គ្រាមឆ្នាំ៧៥ទៅ គាត់បញ្ជូនទៅតាមព្រំដែនណាស់ ។

វណ្ណៈ៖ ចឹងតាឃួនហ្នឹងឆ្នាំ៧៥គាត់នៅជាមួយពូទៀត?

លន់៖ ៧៥ នៅតាមសមរភូមិទេ គាត់ទៅកន្លែងវិញ គាត់ទៅខាងឈើកាច់គាត់គណៈតំបន់ ខ្ញុំគាត់ថាអូនឯងមិនបាច់ទៅជាមួយអ៊ំទេ អូនឯងទៅព្រំដែនទៅ ចាំអ៊ំផ្ញើសំបុត្រឲ្យកាន់ទៅ ខ្ញុំក៏ទៅៗ ។

វណ្ណៈ៖ បាទ!ចឹងក្រោយមកមានដឹងថា តាឃួនហ្នឹងគេចាប់ឬមួយអត់ទេ?

លន់៖ តាហ្នឹងគាត់ឈឺស្លាប់ ។

វណ្ណៈ៖ ចឹងមិនមែនគេចាប់ទេ?

លន់៖ គេអត់មានចាប់ទេ បើមេទាហានខ្ញុំគេហៅទៅរៀន ។

វណ្ណៈ៖ ឈ្មោះអីសារ៉ែនហ្នឹង?

លន់៖ មួយសារ៉ែន មួយ ផុស ។

វណ្ណៈ៖ ចឹង ផុស ហ្នឹងគាត់មានឋានៈអីដែរ?

លន់៖ ផុស ហ្នឹងគាត់ជាលេខា សារ៉ែន ហ្នឹងជាអនុប្រធានយោធា ។

វណ្ណៈ៖ ចឹងជាលេខាយោធា?

លន់៖ លេខាយោធាអាហ្នឹងប្រធាន“ខ” សារ៉ែន អនុ ហើយខាងបងស្នាន់ នោះសមាជិក ។

វណ្ណៈ៖ ឈ្មោះ ស្នាន់ ចាមទេ ឈ្មោះ ស្នាន់?

លន់៖ ខ្មែរយើងហ្នឹងតែឈ្មោះ ស្នាន់ ចឹងអីស្នាន់ទេ ខ្ញុំភ្លេច កម្មាភិបាលមិនសូវស្គាល់ទេហៅយ៉ាងម៉េចឆ្លើយចឹង ព្រោះយើងមិនបានសុំគេមើលដូចជាឥឡូវទេណាស់ ។

វណ្ណៈ៖ ចឹងពូនៅហ្នឹងតាំងពីឆ្នាំ១៩៧៥-៧៦-៧៧ដល់ឆ្នាំណា ព្រោះខ្ញុំធ្លាប់ជួបអ្នកនៅព្រំដែនជាយោធាចឹងច្រើនមានកងពល ខ្លះកងពល៩២០ខ្លះ៨០១អីចឹង?

លន់៖ ទេ ក្រោយៗមកបានមានកងពល ។

វណ្ណៈ៖ ចឹងឆ្នាំណាបានមានកងពល?

លន់: មើលកងពលឆ្នាំណាទេ អាចឆ្នាំ៧៧ នៅកងពល៨០៥ ។

វណ្ណៈ: ចឹងមានកងពល៨០៥ដែរ?

លន់: បាទ!កងពល៨០៥ ។

វណ្ណៈ: ចឹងនៅកងពល៨០៥ហ្នឹងពីណាជាប្រធានកងពល?

លន់: ឈ្មោះ តាសុន សេន តែគ្រាន់តែឮឈ្មោះខ្ញុំមិនដែលស្គាល់ទេ ។

វណ្ណៈ: ចឹង សុន សេន?

លន់: សុន សេន ។

វណ្ណៈ: ចឹងតាសុន សេន ទៅដល់ហ្នឹងដែរ ព្រោះតាសុន សេន តាមដឹងនៅក្នុងឯកសារគាត់បានទៅហ្នឹងមែន ប៉ុន្តែកាលនៅភ្នំពេញគាត់ជាអគ្គមេបញ្ជាការធំនៅសេនាធិការនៅភ្នំពេញតែម្តង?

លន់: ខ្ញុំឮតែ សុន សេន ខ្ញុំមិនដែលស្គាល់ទេ ខ្ញុំបាទឮតែឈ្មោះ ខ្ញុំមិនដែលស្គាល់ទេ ព្រោះយើងនៅតាមកង យើងមិនងាយឃើញស្គាល់គេទេ ។

វណ្ណៈ: ចឹងអនុ សុន សេន ជាពីណា?

លន់: អត់ស្គាល់ ខ្ញុំស្រពិចស្រពិលខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ: ចឹងឆ្នាំ១៩៧៧ហ្នឹងចាប់ផ្តើមវាយជាមួយវៀតណាមហើយឬនៅ?

លន់: វាយតាំងពីឆ្នាំ១៩៧៦នោះ ។

វណ្ណៈ: ចឹង?

លន់: មើល៧៦ហ្នឹងហើយ៧៧-៧៨-៧៩វាយបីហ្នឹងចាប់ផ្តើមវាយហើយ មើលកាលហ្នឹងចាប់វាយឆ្នាំ១៩៧៦ខែប៉ុន្មានទេ ខ្ញុំភ្លេចដែរ ។

វណ្ណៈ: អត់អីទេ ពូ ដូចថាកម្លាំងខ្មែរក្រហមធ្លាប់តែមានឈ្មោះបោះសម្លេងវាយចឹង ដល់ពេល?

លន់: មើលឈប់ៗ និយាយចឹងកាលមុននោះ ខ្ញុំទៅនៅជំបូង ខ្ញុំនៅបានយូរខែដែរ ដល់នេះគេបើកយុទ្ធនាការវៀតណាមវាយខ្មែរយើង ដល់វាយមកហើយមេបញ្ជាការខាងខ្មែរយើងមិនឲ្យវាយ ចឹងរថក្រោះកិនងាប់អស់ ខ្ញុំរត់ដល់ស្វាយរៀង ។

វណ្ណៈ: ចឹង?

លន់: កិនងាប់អស់នៅ“យ៨”ងាប់ចឹងអស់នៅតូចៗទេ ។

វណ្ណៈ: ចឹងយ៉ាងម៉េចបានជាយើងមិនវាយឲ្យគេបរកិនវិញ?

លន់: កាលហ្នឹងមេមិនឲ្យវាយ ។

វណ្ណៈ: ចឹងមេមិនឲ្យវាយឆ្នាំណាឆ្នាំ៧៧ឬ៧៨?

លន់: ឆ្នាំ៧៦-៧៧ហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងវៀតណាមវាយយើងដល់ស្វាយរៀង?

លន់ៈ កាលហ្នឹងរថក្រោះដេញដាន់ម៉ាក្រាំងលាវដេញដាន់ខ្មែរយើងងាប់អស់មួយសារកងទ័ព"យ៨" កូនអ្នកស្រុកបាភ្នំងាប់អស់មិនចេះតិចទេ ខ្ញុំដឹង ខ្ញុំរត់ធ្លាក់ដល់គោកដុកម៉ាវាយហ្នឹងតាំងពីក្រាំងលាវទៅ មិនឲ្យកងទ័ពខ្មែរវាយទេ ងាប់អស់ខ្ញុំទាញកាំភ្លើងដាក់មិនព្រម ខ្ញុំនៅខាងក្រោយទេ គេនៅខាងមុខ សួរអ្នកមុខមើលងាប់ទាំងអស់ ដាន់ងាប់តែម្ដង ។

វណ្ណៈ ចឹងដាន់ហើយរយៈពេលប៉ុន្មានបានដកទៅវិញ?

លន់ៈ គេគ្រាន់តែវាយមួយយប់មួយថ្ងៃដកទៅវិញ បានយើងចរចារណាស់ គេចរចារឲ្យឈប់បាញ់មួយរយៈណាស់ នៅជំនាន់ហ្នឹងមួយដងតាមខ្ញុំដឹងទេ ខ្ញុំធ្វើខ្លួនខ្ញុំ ខ្ញុំដឹង កាលខ្ញុំនៅ"យ៨" ។

វណ្ណៈ បាទ ។

លន់ៈ នៅធ្វើរដើង ។

វណ្ណៈ ចឹងកាលហ្នឹងយួនបររថក្រោះកិនតែម្ដង?

លន់ៈ បាទ!ហ្នឹងកងទ័ពយួន យួននៅត្រពាំងព្រាម អាហ្នឹងបន្ទាយត្រពាំងព្រាម ។

វណ្ណៈ ចឹងក្រោយមកទៀតយើងនិងមានការវាយគ្នាម្ដងទៀតវាយគ្នារហូត?

លន់ៈ មានការចរចារពីរបីថ្ងៃក្រោយមកយើងចរចារឈប់វាយគ្នា នៅការពាររៀងខ្លួន ។

វណ្ណៈ ហើយមានរឿងយ៉ាងម៉េចទៀតទៅ?

លន់ៈ ដល់ក្រោយមកទៀតបាញ់គ្នាជាបន្តបន្ទាប់ ហើយកាលហ្នឹងយើងចេញចូលបានតាមចិត្តហ្នឹងតែខាងវៀតណាម មានតំណាងមេភូមិដូចខ្ញុំចឹងគេមិនឲ្យស្ដីរកទេ មិនឲ្យប្រជាជនស្ដីរកខ្មែរយើងគេហៅតំណាងយៀកគាវ ។

វណ្ណៈ តំណាងយៀកគាវយ៉ាងម៉េចទៅ?

លន់ៈ គេហៅមេភូមិ មេភូមិគេមិនឲ្យស្ដីរក ។

វណ្ណៈ ចឹងយៀកគាវហ្នឹងមានន័យថាមេភូមិ?

លន់ៈ អើ!គេនិយាយចឹង ខ្ញុំមិនសូវដឹងយួន ហ្នឹងជំនាន់ហ្នឹង កាលហ្នឹងខ្ញុំចេញចូលអីបានខ្លះដែរក្រោយមកគេលើកទឹសវាយ ។

វណ្ណៈ ចឹងនៅឆ្នាំណាដែលគេចាប់ផ្ដើមវាយរហូតដល់ឆ្នាំ៧៩ហ្នឹង?

លន់ៈ មើលវាយហ្នឹងមិនដឹងជាឆ្នាំ៧៦-៧៧ ពេលវាយហ្នឹងខ្ញុំច្រឡំដែលហ្នឹង យើងវាយចូលបក្សហើយណាស់ ។

វណ្ណៈ ចឹងពេលដែលវាយហ្នឹងខាងខ្មែរក្រហមធ្លាប់តែមានឈ្មោះល្បីវាយខ្លាំងអីចឹង ពេលវាយជាមួយវៀតណាមហាក់បីដូចជាបាក់ទឹកចិត្តចាញ់ចឹងមកពីមូលហេតុអីមកពីកងទ័ពបាក់ទឹកចិត្តឬ

មួយវាយយ៉ាងម៉េច មិនបានមកលេងផ្ទះសំបែងឬក៏មិនមានការខបត្ថម្ភគ្រប់គ្រាន់តែជាកម្លាំងខ្មែរក្រហមវាយចាញ់វៀតណាម?

លន់: វាចេះដឹបូងវាយលើកដែលប្រយុទ្ធហ្នឹង អាហ្នឹងខ្ញុំបានចូលវាយដែរ ព្រោះខ្ញុំខាងស៊ើបការខ្ញុំអ្នកស៊ើបការវាយខ្លួនឯងតែម្តងខ្ញុំបានវាយជាមួយគេ ពីរបីលើកដែរ ហើយដល់ក្រោយមកកងទ័ពទាំងអស់មិនមានការហូបចុកគ្រប់ទេ កាលមុនហ្នឹងយើងយើងនាំគ្នាលើកប្រព័ន្ធភ្លឺស្រែ ។

វណ្ណៈ: បាទ ។

លន់: លើកប្រព័ន្ធភ្លឺស្រែនេះអាហ្នឹងឆ្នាំ៧៥ចប់ណាស់ លើកប្រព័ន្ធភ្លឺស្រែហ្នឹងកំណត់ថាម្នាក់បាន៣០ម៉ែត្រចឹងណាស់ ទទឹងមួយម៉ែត្រកំពស់៧តឹកខ្នងលើកន្ទះម៉ែត្រ ប៉ុណ្ណក៏៣០ម៉ែត្រដែលក្នុងមួយថ្ងៃ ។

វណ្ណៈ: ចឹងធ្វើហើយទេ?

លន់: ហើយអ្នកមានកម្លាំងហើយ ។

វណ្ណៈ: ចេះពូខ្ញុំចង់ថា ខាងកងកម្លាំងយើងវាយចាញ់វៀតណាម កាលហ្នឹងពូរត់សំដៅទៅស្រុកកំណើតឬពូរត់មកតាមភ្នំពេញហើយរត់មកដល់ជាយដែននេះ?

លន់: ចេះខ្ញុំហ្នឹងប្រវត្តិខ្ញុំហ្នឹង រត់កាលវាយចូលទូទាំងប្រទេស ខ្ញុំរត់តាមព្រំដែនរហូត ខ្ញុំគាត់ឲ្យនៅខាងសេដ្ឋកិច្ចដាំបាយឲ្យគាត់ហូប ដឹកជញ្ជូនគ្រាប់តាមទូកតាមកាណូត ទាំងរទេះទាំងគោទាំងមេគោអីហ្នឹង ។

វណ្ណៈ: អាហ្នឹងខ្ញុំចង់និយាយឆ្នាំ១៩៧៩វិញ ៧៩យួនចូល?

លន់: ហ្នឹងហើយចូលហ្នឹង ។

វណ្ណៈ: ៧៩ វៀតណាមចូលដល់ហ្នឹង?

លន់: បាទ! វៀតណាមចូលតាមផ្លូវដល់អ្នកលឿងអី ខ្ញុំនៅកំពង់តាហ៊ុយនោះ នៅពាមជនោះហើយខ្ញុំបានហែលទឹកមកកោះពាមរាំងហើយបានហែលឆ្លងពីកោះពាមរាំងមកទៀត ។

វណ្ណៈ: ចឹងពូរត់យ៉ាងម៉េចទៀតទៅ ពូរត់មកដល់ព្រៃភ្នំនេះឆ្នាំណាដែរ?

លន់: ខ្ញុំមករហូត៧៩ហ្នឹងមកតាមស្ពានរហូតមក បានមកដល់ភ្នំស្រង់ ។

វណ្ណៈ: ជិះអីខ្លះទៅ?

លន់: ជិះអីដើររត់ហ្នឹងៗរហូតហ្នឹង ។

វណ្ណៈ: ដើរកាត់ព្រៃអត់បាយ?

លន់: អត់រហូតហ្នឹង អត់បាយជួបអីហូបហ្នឹង ជួបជ្រូកកាប់ជ្រូកស៊ីជួបបាយដាំបាយស៊ីហើយចេញទៀតជួនកាលស៊ីមិនទាន់ផង វាយគ្នាទាញមុខទាញក្រោយ អាហ្នឹងវៀតណាមចូលពេញ

ប្រទេសហើយ តាមផ្លូវថ្នល់ជាតិលេខ២លេខ៣មកវាយគ្នាយូរផ្លូវជាតិលេខ៣ វាយកាត់កគ្នា ខ្ញុំវាយៗបានឡើងលើភ្នំស្រង់ ។

វណ្ណៈ៖ ចឹងពូបែកប្រពន្ធកូនរហូត?

លន់៖ បែករហូត ។

វណ្ណៈ៖ ចឹងដល់ពេលណាបានពូជួបគ្នាវិញ?

លន់៖ ជួបគ្នាដល់ខ្ញុំរត់នៅឆ្នាំ៧៩ហ្នឹង ចូល៨០ហ្នឹង ខ្ញុំត្រឡប់ពីព្រៃភ្នំទៅវិញ គេហៅភ្នំ១០០ស្រទាប់ហ្នឹង ខេត្តកំពង់ស្ពឺរហូត ពោធិសាត់ កំពង់ឆ្នាំងអីហ្នឹង បានខ្ញុំឡប់ទៅវិញ ។

វណ្ណៈ៖ ចឹងពូអត់មានបានទៅដល់ព្រំដែនទេ?

លន់៖ អត់ទេ ខ្ញុំមិនបានមកដល់ព្រំដែនទេ ដល់ចឹងខ្ញុំទៅនៅស្រុកក្នុងជនានរដ្ឋកម្ពុជា អាហ្នឹងយើងជិតចូលឆ្នាំ៨០ហើយ ។

វណ្ណៈ៖ ចឹងពូបានត្រឡប់ទៅស្រុកវិញឆ្នាំ១៩៧៩ដដែល?

លន់៖ បាទ!ឆ្នាំ៧៩ ។

វណ្ណៈ៖ ចឹងជិតចូលដល់ឆ្នាំ១៩៨០ ហើយពេលជួបប្រពន្ធកូនពូយ៉ាងម៉េចដែរ ពូអរសប្បាយយ៉ាងម៉េចដែរ?

លន់៖ បាទ!ប្រពន្ធកូននឹកឃើញថា ប្រពន្ធកូនហ្នឹងស្លាប់បាត់អស់ហើយ ចឹងបានថាខ្ញុំបានត្រឡប់ទៅស្រុកវិញបានជួបប្រពន្ធកូនហ្នឹង ហើយក៏ក្រពេកនៅធ្វើស្រែអត់មានគោហើយមិនដឹងថាធ្វើយ៉ាងម៉េច ផ្ទះក៏អត់មាននៅ ដល់ចឹងហើយខ្ញុំដាច់ចិត្តថា កាលហ្នឹងពួកគេចែកអង្កឡស៊ីស្រាប់កាកបាទក្រហមនៅព្រំដែនហ្នឹងណាស់ ក៏នាំប្រពន្ធកូនហ្នឹង កាលនោះកូនមានតែបីនាក់ទេ ទុកកូនពីរនាក់នៅស្រុក នៅជាមួយយាយតា នាំកូនស្រីមួយតូចមកជាមួយមកនៅចម្ការគភ្នំឆ័ត្រហ្នឹង ។

វណ្ណៈ៖ មកនៅណា?

លន់៖ មកនៅចម្ការគភ្នំឆ័ត្រ ។

វណ្ណៈ៖ ឆ្នាំណាពូចេញមកចម្ការគភ្នំឆ័ត្រ?

លន់៖ ខ្ទង់ឆ្នាំ១៩៨១ ។

វណ្ណៈ៖ ចឹងកាលហ្នឹងដោយសារក្របានជាពូរត់?

លន់៖ ក្រពេក ចុះសង្គ្រាមវាអស់រលីងហើយ ខោអាវសឹងថាគ្មានស្លៀក ចុះវាក្រនោះក្រ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានខ្សែរយៈយ៉ាងម៉េចបានជាពូរត់ចូលព្រៃវិញ?

លន់៖ អត់ទេ គ្មានខ្សែរយៈទេ ។

វណ្ណៈ៖  ចឹងដើរផ្សងព្រេង?

លន់៖  ដើរមែនហ្នឹង ដូចក្មួយនិយាយហ្នឹង ។

វណ្ណៈ៖  ចឹងកាលហ្នឹងដាច់ចិត្តចោលកូនដែរ?

លន់៖  ចោលកូន កូនហ្នឹងឲ្យនៅជាមួយយាយពីរទៅ ហើយយកកូនស្រីមួយមកតាមហើយបាននៅចម្ការគក្នុំឆត្រហ្នឹង មិនមានមុនរបរអីទេ គេស្គាល់គ្នាគេស្គាល់ខ្ញុំហ្នឹង ។

វណ្ណៈ៖  ចឹងកាលនៅភ្នំឆត្រហ្នឹងពីណាគ្រប់គ្រងនៅហ្នឹងភ្នំឆត្រ?

លន់៖  កាលហ្នឹងអ៊ីជន ឈ្មោះ ឯក ជន មេជំរំចម្ការគ ។

វណ្ណៈ៖  ចឹងមិនមែនជំរំតាសឺន សាន?

លន់៖  អត់ទេ អាហ្នឹងគេហៅជំរំខ្មែរក្រហមនោះ កាលហ្នឹងគេហៅជំរំកម្ពុជាប្រជាធិបតេយ្យ ។

វណ្ណៈ៖  នៅភ្នំឆត្រហ្នឹង?

លន់៖  បាទ! គេហៅភ្នំឆត្រចម្ការគ ។

វណ្ណៈ៖  ចឹងប្រធានធំដូចជាប្រធានកងពលតែម្ដងពីណាគេទៅ?

លន់៖  តាយន ។

វណ្ណៈ៖  ចឹងមិនមែនតាឌុល សារឿន អីទេ?

លន់៖  សារឿន ខ្វាក់?

វណ្ណៈ៖  បាទ ។

លន់៖  សារឿន ខ្វាក់តាយនជាមួយគ្នាហ្នឹង ។

វណ្ណៈ៖  ចឹងមានតាជនទៀត?

លន់៖  តាជន គាត់កាន់ខាងជំរុំខាងប្រជាជនប្រធានជំរុំឈ្មោះ ឯក ជន ។

វណ្ណៈ៖  ចឹងមានតាឌុល សារឿន មានតាអីទៀត?

លន់៖  មានតាសារឿន តាអីទៀតខ្ញុំមិនសូវស្គាល់ទេ មានតាស៊ូ ។

វណ្ណៈ៖  តាស៊ូតាសារឿនគាត់នៅតើ?

លន់៖  បាទ! នៅ ។

វណ្ណៈ៖  ចឹងកាលពូទៅដល់ភ្នំឆត្រហើយយ៉ាងម៉េចបានជាពូគ្មានបំណងចង់រត់ទៅប្រទេសទីបីចេញទៅក្រៅបន្តទៀត?

លន់៖  វាមិនមានគ្មានខ្សែរយៈ បើគ្មានខ្សែរយៈមិនបានទៅទេ កាលជំនាន់នោះអ្នកនៅស្រះកែវកាំពុតគេដឹកទៅអាមេរិចហើយ ។

វណ្ណៈ៖  បាទ ។

លន់៖ ចឹងណាស់ អ្នកណាចង់មកខ្មែរវិញឲ្យមកខ្មែរវិញឲ្យទៅស្រុកវិញ ហើយចឹងខ្ញុំចេញទៅពីស្រុកខ្មែរយើងនៅទៅព្រំដែនហ្នឹង គេមកពីស្រះកែវកាំពុតហ្នឹងចូលមកស្រុកខ្មែរយើងចឹងណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ ហើយគេមិនអាចដឹកយើងបានទៅទេ ព្រោះអាមេរិចវាសាបរលាបចង់ថាគេមិនអាចយកខ្មែរទៅទៀតទេ គេឲ្យខ្មែរត្រឡប់មកវិញ ចឹងយើងថាយើងស្ម័គ្រចិត្តចុះ ហើយជំរុំហ្នឹងជាជំរំរបស់ខ្មែរ ។

វណ្ណៈ៖ ចឹងខាងអាមេរិចខាងអូស្រ្តាលីគេទទួលយើងបានតែថ្មីទេ?

លន់៖ បាទ ។

វណ្ណៈ៖ ចឹងមុនដំបូងគេចាត់ថាយើងរងគ្រោះ?

លន់៖ យើងរងគ្រោះ កាលគេរត់ទៅឆ្នាំ១៩៧៩-៨០អីហ្នឹង គេរត់ទៅនៅកាំពុតស្រះកែវហ្នឹងគេប្រកាសមេក្រូថានរណាចង់ទៅខ្មែរក៏ទៅនរណាចង់ទៅអាមេរិចទៅជប៉ុនទៅថៃអីណាគេបើលឲ្យទៅ ចង់ទៅណាគេដឹកទៅហ្នឹង ចឹងណាស់ ចង់ទៅខ្មែរវិញគេឲ្យមកនៅព្រំដែនវិញ ហើយជនាន់ខ្ញុំទៅហ្នឹង ខ្ញុំទៅនៅជំរំខ្មែរ បំណងទៅរកស៊ីទេវាអត់ ហើយចុះបាតដៃទទេហ្នឹង កាលហ្នឹងខ្ញុំទៅគេឲ្យខ្ញុំធ្វើគ្រូបង្រៀនក្មេង ។

វណ្ណៈ៖ ចឹងកាលពូចូលដល់ជំរំភ្នំឆ័ត្រចឹង ចឹងមានចូលទៅក្នុងកងទ័ពអីទៀតហើយ?

លន់៖ អត់ទេ ខ្ញុំនៅខាងរដ្ឋបាលខាងគ្រូ ។

វណ្ណៈ៖ ចឹងពូអត់មានបានឡើងវាយចូលទ័ពទៀតទេ?

លន់៖ អត់ទេ ។

វណ្ណៈ៖ អត់រហូតដល់ឥឡូវនេះ?

លន់៖ បាទ!អាហ្នឹងខ្ញុំវែងឆ្ងាយដែលហ្នឹង ហើយពីហ្នឹងទៅយួនកាលហ្នឹងកងទ័ពខាងរដ្ឋាភិបាលហ្នឹងវាយគេដឹកខ្ញុំទៅនៅម៉ាឡៃនោះ ។

វណ្ណៈ៖ ខាងណាវាយ?

លន់៖ ខាងរាជ្យរដ្ឋាភិបាលវាយទៀតមិនទាន់អស់ទេ ។

វណ្ណៈ៖ វាយនៅចម្ការគភ្នំឆ័ត្រហ្នឹង?

លន់៖ វាយនៅចម្ការគភ្នំឆ័ត្រហ្នឹង វាយអស់ប្រជាជននៅជំរុំហ្នឹង ។

វណ្ណៈ៖ ចឹងរត់ទៅថៃទៅ?

លន់៖ រត់ទៅនៅថៃ ថៃពួកទ័ពសៀមណាស់ ថៃបាញ់ផាប់រាល់ថៃ ឲ្យតែជាន់ដើមឈើវាមួយដើមវាឲ្យសង៥០០បាត ចោរប្លន់ហារយ ប្លន់មួយយប់៣០ទៅ៤០នាក់ចោរ ។

វណ្ណៈ៖ ចឹងវេទនាដែរ?

លន់៖ វេទនាដែលអី វេទនាតែម្តងហ្នឹង ស្រាតខោអាវអស់ដេកផ្កាប់មុខនោះប្រុសៗវាយសុទ្ធតែគល់កៅស៊ូ សុទ្ធតាំភ្លើងគ្រប់ដៃ មានប្រដាប់វាយ ចោរហាវយខ្ញុំជួបហើយ ។

វណ្ណៈ៖ បាទ ។

លន់៖ ហើយពីហ្នឹងទៅបានគេប្រកាសមេក្រូថា នរណាទៅសម្ពន្ធាញ់ ទៅសាយធូ ទៅភ្នំដងរែកអីចឹងទៅ ទៅម៉ាឡៃចឹងទៅ គេប្រកាសមេក្រូ ដូចថាខ្ញុំចង់ទៅម៉ាឡៃចឹង ឡានគេមកឡើងឡានម៉ាឡៃទៅ ឡានសាយធូៗ ឡានសម្ពន្ធាញ់ៗចឹងណាស់ ដូចគេលក់ពងទាចឹង ។

វណ្ណៈ៖ ចឹងនៅឆ្នាំណាដែលខាងរដ្ឋាភិបាលវាយធ្លាយដល់ជាយដែនហើយចូលដីថៃអីហ្នឹង?

លន់៖ អាហ្នឹងដល់ជាយដែលហ្នឹងមួយសារ ។

វណ្ណៈ៖ ឆ្នាំណា ពូបានចាចេញពីចម្ការគទៅម៉ាឡៃ?

លន់៖ យី!ដូចជាឆ្នាំ៨០ប៉ុន្មានទេ ដូចបានទៅនៅហ្នឹងបានតែបីឆ្នាំទេ ឆ្នាំ៨៥មិនដឹងទេ ។

វណ្ណៈ៖ ប្រហែលជាពូនិយាយអាចត្រូវ ព្រោះឆ្នាំ១៩៨៥កម្លាំងខាងរដ្ឋាភិបាលវាយធ្លាយសឹងតែគ្រប់ច្រកទាំងអស់តាមព្រំដែន?

លន់៖ បាទ ។

វណ្ណៈ៖ ឲ្យតែខ្មែរក្រហមនៅតាមព្រំដែនសឹងថានាំគ្នារត់ចូលថៃសឹងតែទាំងអស់?

លន់៖ អាហ្នឹងមួយចាំស្តាប់ខ្ញុំនិយាយណាស់ អាហ្នឹងវាយហើយដឹកទៅម៉ាឡៃហើយអ្នកទៅសម្ពន្ធាញ់អ្នកទៅសាយធូៗ ទៅដងរែកៗ ហើយខ្ញុំហ្នឹងទៅខាងម៉ាឡៃ ទៅដល់ម៉ាឡៃហើយទៅហ្នឹងចូលខ្មែរក្រហមនៅហ្នឹងដូចជិនាន់បីឆ្នាំ អត់មានខុសគ្នាទេ ។

វណ្ណៈ៖ នៅម៉ាឡៃហ្នឹង?

លន់៖ បាទ!ទៅដល់ម៉ាឡៃជាមួយតាអៀង សារី ហ្នឹង អត់មានខុសគ្នាទេ សូម្បីផ្ញើរបងចាក់ចំរូងទៅចាក់កន្លែងយើងដងទឹកខ្លាចយើងរត់ តែយើងចាក់ខ្លួនយើងទេ តាមអូរចាក់ចំរូងទាំងអស់ចឹងជុំវិញហ្នឹង ហើយគេបើកអង្ករឲ្យហូប ហើយអង្ករជំនាន់ហ្នឹងមានបារាំងបើកតាមជួយប្រជាជនកាលក្រណាស់ តែអង្ករហ្នឹងយើងមិនបានហូបទេ គេដូរឲ្យអង្ករចិនណាស់ អង្ករចិនមិនខុះទេ អង្ករចិនសដូចឆ្អឹងចឹង តែស៊ីវាមិនដូចអង្ករបារាំងគេបើក អង្ករបារាំងបើកឲ្យវាមានជាតិកន្ទក អង្ករចិនទឹកថ្នាំហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងចំរូងគេឲ្យយើងបិទរបៀបយ៉ាងម៉េចដែរ?

លន់៖ បិតចំរូងយើង ។

វណ្ណៈ៖ ប្រវែងណា?

លន់៖ មួយចង្អាម ។

វណ្ណៈ៖ ពីរតឹកឬបីតឹក?

លន់៖ មិនបានបីតឹកទេ ប្រហែលជាមួយតឹកកន្លះអីពីរតឹកហ្នឹង ។

វណ្ណៈ៖ ចឹងយើងដាក់ចូលក្នុងដីនោះ?

លន់៖ ដាក់ក្នុងដីតែមួយដាប់ៗទៅ មានទៅវាយស្អុ ។

វណ្ណៈ៖ គេធ្វើយ៉ាងម៉េចគេយកអីបិតទៅ ចំរូងហ្នឹង?

លន់៖ បិតឬស្សីយកមកពុះហើយ ធ្វើចេះដាក់កាំបិតចឹងដាក់ដាប់និងកាំបិតចឹងហើយស្រកត់ទាញចឹងទៅ ។

វណ្ណៈ៖ ចឹងបិតឲ្យស្រួចចុងដើមទៅ?

លន់៖ បាទ!បិតឲ្យស្រួចចុងដើមបានយើងដោត ។

វណ្ណៈ៖ ចឹងមានប្រសិទ្ធភាពទេចំរូងហ្នឹង?

លន់៖ មានតើ គេដើរដាន់ដាក់ទៅតាមដងអូរតាមផ្លូវដូចថាផ្លូវភូមិ ដូចថាធ្វើរបងភូមិចឹង បើថាកន្លែងទឹកចឹងយើងចាក់ជុំវិញទៅ តាមអូរស្រឡៅហ្នឹងណាស់ ហើយដល់ព្រឹកឡើងយើងទៅដកវិញដងទឹក ហើយដល់ក្រោយមកយួនវាយបែកទូទាំងប្រទេស ទូទាំងព្រំដែនអស់រលីងបែកអស់ ចូលទៅថៃ និយាយពីថៃប្អូនគ្មានសល់អីទេ ឈរប្អូនទាំងខ្សែតែម្តងឃើញអីយកហ្នឹងថៃប្អូន ទាល់តែខាងអង្គការខាងកាកបាទមកទាន់បានឈប់ ឲ្យតែឃើញឡានទង់ជាតិសញ្ញាលេខបូកឡានសហ្នឹងឈប់ហើយ ។

វណ្ណៈ៖ ចឹងកាលពូទៅនៅម៉ាឡៃហ្នឹងមានដឹងថា កាលហ្នឹងមានពុកសម្តេចតាទៅកន្លែងគេហៅអីទេ?

លន់៖ ទៅប្រជុំហ្នឹងឯង ។

វណ្ណៈ៖ ហ្នឹងហើយសម្តេចតាទៅកន្លែងហ្នឹងគេហៅអី?

លន់៖ គេហៅភូមិដូង ។

វណ្ណៈ៖ ភូមិដូងតែកន្លែងហ្នឹងគេហៅសាតាំងអីនោះ ពូមានធ្លាប់ឮសាតាំងទេ កាលហ្នឹងគេរៀបសាតាំងសម្តេចចុះទៅនោះ ពូមានទៅទទួលគាត់ទេ?

លន់៖ ខ្ញុំអត់បានទៅទទួលទេ កាលហ្នឹង ព្រោះខ្ញុំឈឺជើងខ្ញុំមិនបានទៅទេ តែសម្តេចមកប្រជុំហ្នឹងម្តងកាលហ្នឹងគេធ្វើដំណាក់សម្តេចអីកាលហ្នឹង ។

វណ្ណៈ៖ ចឹងកាលពូនៅម៉ាឡៃហ្នឹងពូនៅតែសមរភូមិក្រោយទេ?

លន់៖ ខ្ញុំនៅក្រោយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងនៅជាមួយតាអៀង សារី?

លន់: ខ្ញុំនៅតាមកងទេ នៅប្រជាជន។

វណ្ណៈ: ចឹងតាប៉ុល ពត អីគាត់នៅខាងហ្នឹងដល់ក្រោយមកគាត់មកនៅនេះវិញ?

លន់: អត់ទេ ប៉ុល ពត អត់មាននៅហ្នឹងទេ។

វណ្ណៈ: ចឹងតាខៀវ សំផន តាសុន សេន អី?

លន់: មិននៅទេ នៅតែអៀង សារី។

វណ្ណៈ: ចឹងតាសួរ ហុង ពូមានស្គាល់ទេ តាចៀមអី?

លន់: តាចៀម អីនៅហ្នឹង ព្រោះខ្ញុំស្គាល់ម៉ែមាន់អីនៅហ្នឹងដែរ ខ្ញុំខស្សរាហ៍ទៅលេងតែគាត់ខាងគ្រូសាស្ត្រាចារ្យដែរ។

វណ្ណៈ: ចឹងកាលហ្នឹងចំរូងគេឲ្យយើងបិតក្នុងមួយថ្ងៃឲ្យបានប៉ុន្មានដែលពូ?

លន់: វាមិនកំណត់ទេ ជួនណាយើងឆ្លៀតពេល សល់ពេលចឹងទៅយើងធ្វើ៥០ទៅ១០០អីទៅមីង១ឲ្យលើកជួរនៅចាំផ្ទះនៅលើកជួរខ្វនឯងចឹងទៅណាស់ ហើយការហ្នឹងដីស្អិតព្រៃគេមិនឲ្យកាប់ទេ ព្រោះកាលហ្នឹងព្រៃណែនចេះ។

វណ្ណៈ: ចឹងព្រៃច្រើនមែនទែន ហើយគេថាចាញ់?

លន់: ចាញ់ខ្លាំងណាស់ ចាញ់ជ្រុះសក់អស់ ចាញ់ណាស់នៅម៉ាឡៃ។

វណ្ណៈ: ចឹងកាលហ្នឹងពូនៅម៉ាឡៃរហូតឬមានការបកត្រឡប់មកខាងនេះវិញ?

លន់: ចាំមើលខ្ញុំនិយាយនៅម៉ាឡៃហ្នឹងដល់ក្រោយមកកងទ័ពខាងរដ្ឋាជិបាលវាយម្តងទៀតវាយហ្នឹងអស់តាមព្រំដែនរលីងតែម្តង ខាងរដ្ឋាភិបាលលោកហ៊ុន សែន ហ្នឹងវាយអស់ចាប់ផ្តើមដាក់មីនជិនាន់«ក៥»ហ្នឹង ទទឹង៥០ម៉ែត្រ បណ្តោយតាមព្រំដែនរហូតហ្នឹងជំនាន់ហ្នឹង ខ្ញុំទៅនៅជំរុំទី៨។

វណ្ណៈ: ជំនាន់«ក៥»ហ្នឹង?

លន់: បាទ។

វណ្ណៈ: ជំរុំទី៨នៅណាវិញ?

លន់: ជំរុំទី៨គេហៅជំរុំតាផ្មុក ដូចថាម៉ាឡៃចឹងហួសទៅចេះ ហួសទៅលិចនោះ ទៅនៅបារាំងធ្លាក់ដូចចម្រៀងគេច្រៀងហ្នឹង។

វណ្ណៈ: ចេញពីម៉ាឡៃទៀត?

លន់: ចេញពីម៉ាឡៃគេដឹកទៅភ្នំតាផ្មុក ហៅជំរុំទី៨ ថៃគេហៅសៃប៉ែតនោះអង់គ្លេសគេហៅសាយអេកនោះ។

វណ្ណៈ: ចឹងដល់ជំរុំទី៨ហើយឆ្នាំណាបានពូផ្លាស់ផ្លូត្រឡប់មកនៅទីនេះ រស់នៅហ្នឹងតែម្តង?

លន់៖ កាលហ្នឹងសង្គ្រាមខ្លាំងហើយ ខ្ញុំទៅនៅហ្នឹងធ្វើការខាងអង្គការវៃបុគ្គលិកវៃ ។

វណ្ណៈ៖ ចឹងពូបានចូលធ្វើការក្នុងអង្គការទៀត?

លន់៖ បាទ!នៅខាងអង្គការវៃ ជាមួយលោកស្រី អង ធ្វើនៅអង្គការវៃ ហើយចេះតែជួយបម្រើការងារប្រទេសជាតិតែមិនដឹងថាខុសត្រូវអីទេ ចេះតែធ្វើទៅយកបាយហូប ជួយបម្រើប្រជាជនយើងខ្លះចឹងទៅ បានខ្លួនឯងរស់ខ្លះចឹងទៅអាហ្នឹងចឹង ថាទៅកាលៈទេសៈរបស់ប្រទេសជាតិ យើងមិនដឹងទៅជាយ៉ាងម៉េចដែលចេះតែធ្វើៗទៅ ។

វណ្ណៈ៖ ចឹងនៅធ្វើអង្គការវៃបានរយៈពេលប៉ុន្មានបានមានការផ្លាស់ប្តូរត្រឡប់ទៅស្រុកវិញឬមួយយ៉ាងម៉េច?

លន់៖ ឆ្នាំ១៩៨៧ចប់អង្គការវៃ ហើយបានចូលខាង«អិនអេ»ទៀតខាងបើកអង្ករឲ្យប្រជាជនហូបទទួលអ្នកមកពីស្រុកណាៗថ្មីកាលហ្នឹង ឆ្នាំ៩០ប៉ុន្មានត្រឡប់មកវិញគេដឹកមកស្រុកវិញ ទៅស្រុកវិញឆ្នាំ១៩៩១ ។

វណ្ណៈ៖ ចឹងឆ្នាំ១៩៩១ហ្នឹងពូធ្វើមាតុភូមិនិវត្តន៍ទៅស្រុក?

លន់៖ បាទ!កាលហ្នឹងមានតុភូមិនិវត្តន៍នៅ៩១ហ្នឹងហើយឬបោះឆ្នោត៩១ ។

វណ្ណៈ៖ បោះឆ្នោតឆ្នាំ១៩៩៣?

លន់៖ ចឹងទៅឆ្នាំ១៩៩១ចឹងហើយ ។

វណ្ណៈ៖ កាលហ្នឹងមានមាតុភូមិនិវត្តន៍មុនបានមានការបោះឆ្នោត?

លន់៖ ហ្នឹងហើយមុនចឹង៩១ហ្នឹងហើយ អាហ្នឹងចេញពីហ្នឹងមកនៅស្រុក ។

វណ្ណៈ៖ ចឹងទៅនៅស្រុកកំណើតវិញបានជួបកូនចៅវិញហើយ?

លន់៖ ហ្នឹងហើយជួបកូនចៅវិញទាំងអស់ ។

វណ្ណៈ៖ ចឹងពេលទៅនៅស្រុកបានធ្វើអីទៀតបានត្រឡប់មករស់នៅទីនេះវិញទៀត?

លន់៖ ចេះទៅនៅស្រុកដូចថាដីធ្លីគេនៅហ្នឹង គេនៅអស់ហើយ ខ្ញុំក៏នៅស្រុកមួយរយៈមកនៅអ្នកលឿងរកស៊ីមួយរយៈ ។

វណ្ណៈ៖ ហើយយ៉ាងម៉េចទៀតពូ?

លន់៖ បានគេផ្តាច់ខ្លួនបានខ្ញុំត្រឡប់មកនៅនេះ ។

វណ្ណៈ៖ ចឹងពេលពូមកនៅនេះពេលសមាហរណ៍កម្មហើយ?

លន់៖ បាទ!ពេលហ្នឹងគេផ្តាច់ខ្លួនអស់ហើយគេថា ឈប់មានការហ្នឹងគេកំពង់ចរចារកផ្ទៃពតាម៉ុកហ្នឹងវាយកផ្ទៃពនេះវិញណាស់ ពួកគេផ្តាច់ខ្លួនគេមកវិញអស់ហើយណាស់ ហើយខ្ញុំក៏មកតាមជាមួយគេហ្នឹងទៅ មករកទឹកដីខ្លួនឯងតែម្តងណាស់ បើនៅស្រុកកំណើតអត់មានសោះ ។

វណ្ណៈ	ចឹងពូមកសម័យផ្តាច់ខ្លួនហើយទេ?

លន់:	បាទ ។

វណ្ណៈ	បើមកមុនហ្នឹងក៏ចូលមិនចុះដែរ?

លន់:	ចូលមិនចុះទេ ហ្នឹងណាខ្ញុំនៅនោះ នៅម៉ាឡៃ នៅកាង៉ុកនោះ ។

វណ្ណៈ	តែពូធ្លាប់ទៅខាងម៉ាឡៃដែរ តែពូមិនទៅនៅខាងនោះវិញ បែជាមកខាងនេះវិញ?

លន់:	បាទ!មកនេះវិញ ។

វណ្ណៈ	មានបងប្អូនខ្មែរយេៈនៅនេះ?

លន់:	មានមិត្តភក្តិធ្លាប់នៅម៉ាឡៃជាមួយគ្នា ហើយគេមកធ្វើទាហានធ្វើទ័ពនៅនេះ ។

វណ្ណៈ	ចឹងគេហៅមកទៅ?

លន់:	គេផ្ដាំថាឥឡូវមកនៅនេះវិញមក ។

វណ្ណៈ	ចឹងពូមកបានកសាងមានដីមានធ្លី?

លន់:	បាទ ។

វណ្ណៈ	ចឹងពូបានដីច្រើនទេ បានដីប្រហែលជាប៉ុន្មានហិចតាដែលរាល់ថ្ងៃ?

លន់:	បាន១០ហាត់ដែរ មកទល់សព្វថ្ងៃហ្នឹងឯង ។

វណ្ណៈ	ចឹងកូនចៅមកនៅជាមួយពូអស់ហើយ?

លន់:	មកអស់ហើយ មានពីណានៅទេ បានធ្វើផ្ទះធ្វើសំបែងអី មានឈើមានដីធ្វើស្រែធ្វើអីណាស់ នេះខ្ញុំរស់នៅខ្លួនឯងតែម្ដង ។

វណ្ណៈ	បាទ ។

លន់:	យើងអត់មានអីហើយទាល់តែមករកចឹង បើចូលផ្សារយើងអត់មានចំណេះ គ្មានការងារធ្វើអី កើតចឹង មានការលក់ដូរមានការស៊ីឈ្នួលគេកូនចៅមិនបានរៀនសូត្រ ចឹងកាត់មកនៅសង្កាត់មាត់ញកចឹងទៅកូនបានរៀនចេះដឹងខ្លះ បើមិនបានខ្ពង់ខ្ពស់ក៏បានចេះមើលរួច ។

វណ្ណៈ	ចឹងកូនចៅពូរៀនបានត្រឹមកំរិតណាដែរ?

លន់:	បានត្រឹមថ្នាក់ទី៨មិនបានដល់ថ្នាក់ទី៩ទេ កាលហ្នឹងសាលាយើងនៅឆ្ងាយ សាលាមានតែនៅត្រពាំងប្រាសាទនោះ ហើយចម្ងាយពីនេះទៅត្រពាំងប្រាសាទ១៦គីឡូ ទៅមកយប់រហូតទៅពីងងឹតមកវិញយប់ពិបាក តែបើសាលាឥឡូវយើងមានជិតៗមានបឋមជិតៗមានអនុវិទ្យាល័យជិតៗឥឡូវមាននៅក្នុងឃុំនេះមានចម្ងាយពីរបីគីឡូម៉ែត្រ ចឹងបើអត់មានអីជិះក៏យើងដើរទៅរៀនបានដែរ ។

វណ្ណៈ	ចឹងពូរាល់ថ្ងៃហ្នឹងមានបានរៀនកូនចៅបានប៉ុន្មាននាក់ដែរ?

លន់៖ រៀបបានបួននាក់ហើយ ។

វណ្ណៈ៖ ចឹងបានបែកផ្ទះខ្លះហើយ?

លន់៖ បែកបីបួននាក់ហើយ ។

វណ្ណៈ៖ ចឹងពូគិតថា សៀវភៅប្រវត្តិសាស្ត្រទាក់ទងសម័យកាលទាំងអស់ហ្នឹង បើយើងបញ្ចូលទៅតាមសាលាឲ្យក្មេងៗបានរៀនសូត្រចឹង ពូគិតថាវាមានផលប្រយោជន៍អីដែរឬក៏យ៉ាងម៉េចពូ បើតាមពូយល់?

លន់៖ ក្មេងៗពុវានិយាយខ្លះហើយ មានប្រវត្តិ និយាយពីប្រវត្តិវានិយាយថាពិបាកណាស់ ចឹងបានថាវាមានចំណេះដឹងតៗគ្នាទៀតទៅតាមការនិយាយចឹងមក ដូចយើងជំនាន់ជប៉ុន ជំនាន់ឥស្សរះចឹង ។

វណ្ណៈ៖ បាទ ។

លន់៖ តាយាយយើងតែងនិយាយប្រាប់ចឹង ។

វណ្ណៈ៖ ចឹងពូគិតថាការរៀនសូត្រកូនចៅឲ្យមានការខ្ពង់ខ្ពស់ទៅពូគិតថា មានប្រយោជន៍អីដល់សង្គមដល់ប្រទេសជាតិដល់ខ្លួនឯងដែលពូ?

លន់៖ អាហ្នឹងវាមានផលប្រយោជន៍ដល់ប្រទេសជាតិផងដល់ខ្លួនឯងផងដល់គ្រួសារផង ដល់ប្រទេសជាតិជាធំហ្នឹងគឺយើងមានទំនុកចិត្តថាយើងអាចកសាងសុភមង្គលកូនចៅតទៅមុខទៀត ព្រោះអត់បេះដឹងល្ងង់ ដូចអ្នកដឹកនាំសម័យបីឆ្នាំ ប្រើកាប់សម្លាប់គ្នាគ្មានការរីកចំរើនទេ មានការប្រណែននិន្ទាគ្នាចង់ចាញ់ចង់ឈ្នះគ្នា ។

វណ្ណៈ៖ ចឹងពូគិតថា ឥឡូវយើងលែងមានសង្រ្គាមអី ពូគិតថាប្រទេសជាតិយើងមានការរីកចំរើនទៅឲ្យយើងរស់បានស្រួលជាងសម័យមុនដែលពូ?

លន់៖ រស់ស្រួលនោះវាលើសពីស្រួលហើយ វាគ្មានអីលំបាកទេ សង្រ្គាមក៏អត់មានពីណាជិះជាន់យើង យើងទៅរកហូបខ្លួនឯង ហើយក្នុងបច្ចុប្បន្ននេះក្នុងសង្គមសម័យនេះប្រទេសពិភពលោកគេគាំទ្រប្រទេសខ្មែរយើង ចូលអង្គការសហប្រជាជាតិហើយគ្មានការអីលំបាកទៀតទេ ឲ្យតែយើងជួយខ្លួនយើងបាន យើងហូបគ្រប់គ្រាន់ដេកនៅស្រួលស្លៀកពាក់ មិនដែលឃើញមានប្រណាស់ផង ខោអាវយើងស្លៀក៤ទៅ៥០០យើងទិញស្លៀកបាន មិនដូចជំនាន់នោះគេឲ្យស្លៀករយើងរយោងប៉ះរែកមិនរួច រកកន្លែងប៉ះមិនឃើញ ។

វណ្ណៈ៖ ចឹងបើនិយាយរឿងស្លៀកពាក់តាមប្រពៃណីខ្មែរយើងវិញ ដូចជាពូអីធ្លាប់ឆ្លងកាត់តាំងពីសម័យសម្តេចមក ហើយសម័យខ្មែរក្រហម មកដល់សម័យឥឡូវ ចឹងខ្ញុំចង់សួរថា កាលសម័យសម្តេចសីហនុហ្នឹង យើងមានការស្លៀកពាក់សមរម្យដែលអត់កាលសម័យហ្នឹង?

លន់៖ បើយើងទំលាមទំលាប់ខ្មែរយើងជនបទត្រឹមត្រូវល្អណាស់ ចូលតាមប្រពៃណីខ្មែរអាវវែងខោវែងសូម្បីតែយើងស្លូងប្រុស ស្ត្រីត្រូវមានអាវវែង តែមកឥឡូវនេះកំរមានអាវវែងណាស់ ។

វណ្ណៈ៖ ចឹងសម័យឥឡូវនេះខុសគ្នាជាមួយសម័យមុន?

លន់៖ បាទ!សម័យមុនស្លៀកពាក់សមរម្យ សម័យមុនមានខ្លួនមានអីសម័យឥឡូវគេពាក់តែមួកខ្លីៗទេ ។

វណ្ណៈ៖ ចឹងកាលសម័យខ្មែរក្រហមវិញ ស្លៀកពាក់យ៉ាងម៉េចដែលការហ្នឹង?

លន់៖ ស្លៀកពាក់ខ្មៅ ។

វណ្ណៈ៖ ខ្មៅសុទ្ធ?

លន់៖ បាទ!ខ្មៅសុទ្ធ គេថាបើយើងអត់មានខ្មៅទាល់យើងជ្រលក់ដើមគ្រោះ ។

វណ្ណៈ៖ ចឹងសម័យខ្មែរក្រហមអត់មានភ្លេងភាត់ការតាមប្រពៃណីខ្មែរយើងទំលាមទំលាប់ក៏អត់មានដែរ?

លន់៖ អត់មានទេ ភ្លេងភាត់ប្រពៃណីមានតែខាសិល្បៈគេនោះ គេសម្លែងរឿងលេងរឿងអីចឹងណាស់ ។

វណ្ណៈ៖ ចឹងបើយើងចង់ការកូនចៅអត់មានភ្លេងតុការអីទេ?

លន់៖ អត់មានទេ ។

វណ្ណៈ៖ ចឹងកាលសម័យសម្តេចសីហនុមាន?

លន់៖ មានគ្រប់គ្រាន់ មានច្រើនការទាល់តែបីថ្ងៃនោះ ។

វណ្ណៈ៖ ចឹងឥឡូវនេះក៏មានដែរ?

លន់៖ មាន តែឥឡូវមានវាគ្រាន់ថារបស់ល្អទំនើបគេធ្វើរហ័ស គេមិនបាច់យកអ្នកចំរៀងមកក៏មានបានរាំដែលចឹងណាស់ បើពីដើមទាល់តែយកអ្នកចំរៀង ។

វណ្ណៈ៖ កាលពីដើមពុថាមានបុកលាក់អីនោះ?

លន់៖ បាទ!ពីដើមគេធ្វើតាមប្រពៃណីច្រើនណាស់ ឥឡូវយើងកាត់ធ្វើម៉េចឲ្យពេលវេលាបង្រួមខ្លីឆាប់រហ័ស ។

វណ្ណៈ៖ ចឹងពាក់ព័ន្ធនិងប្រពៃណីសាសនាទំលាមទំលាប់វិញ ដូចថារាល់ថ្ងៃហ្នឹងពូកាន់សាសនាអីដែរ?

លន់៖ ខ្ញុំកាន់សាសនាព្រះពុទ្ធ សាសនាខ្មែរយើង ។

វណ្ណៈ៖ ចឹងពូគិតថា យើងគោរពសាសនាព្រះពុទ្ធហ្នឹង តើសាសនាហ្នឹងអាចមានផលប្រយោជន៍អីសម្រាប់ខ្លួនយើង អាចនាំផលអីមកដល់ខ្លួនយើងដែរ បើតាមពូយល់?

លន់៖ អាហ្នឹងបើតាមខ្ញុំទេ តាំងពីយាយតាមក គឺព្រះពុទ្ធសាសនាហ្នឹង យើងគោរពព្រះពុទ្ធសាសនា ដើម្បីសាមគ្គីភាព ឯកភាពគ្នាឲ្យស្គាល់ចាស់ទុំ ឲ្យស្គាល់ថាពីណាបងពីណាប្អូនចឹងណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ កាលណាខ្មែរយើងគ្មានសាសនា មានសាសនាប៉ុណ្ណឹងហើយនៅមានពួកពាលអីជ្រែតជ្រែកចឹងណាស់ មិនចេះខ្លាចបាបកាប់សម្លាប់គ្នា មើលកន្លងមកមួយរយៈបីឆ្នាំយើងអត់មានព្រះពុទ្ធសាសនាអត់មានពីណាដឹកនាំពីណា គិតតែពីកំហឹងទល់កំហុលរៀងខ្លួនចឹង ត្រឹមមេក្រុមអាចសម្លាប់បានដែរ តែឥឡូវយើងមានសិទ្ធមនុស្ស មានគោរពព្រះពុទ្ធសាសនាធ្វើច្រើនមួយឆ្នាំពីរឆ្នាំយើងប្រូតកាត់ហើយចឹងយើងធ្វើបុណ្យដាលានការជួបជុំគ្នាសាមគ្គីគ្នា ។

វណ្ណៈ៖ បាទ ។

លន់៖ យើងជាអ្នកគាំទ្រព្រះពុទ្ធសាសនា ខ្មែរយើងបើអត់មានព្រះពុទ្ធសាសនាមិនដឹងទៅជាស្អីទេ ។

វណ្ណៈ៖ ចឹងកាលជំនាន់ដើមអ្នកដែលគោរពសាសនាទៅវត្តអីហ្នឹងមានលក្ខណៈល្អប្រពៃដូចឥឡូវដែរ?

លន់៖ កាលពីដើមខ្លាចបាប គោរពណាស់ ។

វណ្ណៈ៖ ចឹងសម័យខ្មែរក្រហមអត់មានសាសនាហ្នឹងបានធ្វើឲ្យមានមនុស្សស្លាប់អីហ្នឹង ដោយសារយើងអត់ខ្លាចបាបហ្នឹងដោយសារអត់មានសាសនា?

លន់៖ ចុះបើវិទ្យុអត់មានស្តាប់ផង អត់មានការណែនាំពីអ្នកអត់ចេះអក្សរចឹង ហើយម្យ៉ាងស្រុកយើងកើតសង្គ្រាមផង ការផ្តូផ្លាស់ពីសង្គមមួយទៅសង្គមមួយរយៈពេលខ្លីៗហើយមិនបានដឹងថានរណាអាក្រក់នរណាល្អយ៉ាងម៉េច ហើយគេច្រើននិយាយថា ជំនាន់សង្គ្រាមហ្នឹងមានមិត្តមានសត្រូវ មានមិត្តមានខ្មាំងហ្នឹង ។

វណ្ណៈ៖ បាទ ។

លន់៖ ហ្នឹងហើយជំនាន់ហ្នឹងឯង ហើយការពិតមែន ។

វណ្ណៈ៖ ចឹងមកដល់សព្វថ្ងៃនេះ ដូចថាអ្នកជិតខាងអីយើងរាប់អានយ៉ាងម៉េចដែរ?

លន់៖ មានអីយើងរាប់អានគ្នាធម្មតា យើងសាមគ្គីគ្នា ខ្វះខាតអីយើងរកគ្នា ពេលប្រូតកាត់អីយើងយកដៃគ្នាទៅវិញទៅមកចឹង បាយហូបរៀងៗខ្លួនផលប្រយោជន៍អីជួយមើលគ្នាចឹង ដូចថារបស់ទ្រព្យគោក្របីអី យើងនិយាយថា រាប់អានគ្នាសាមគ្គីធ្វើម៉េចឲ្យបានជឿនលឿន កុំឲ្យមានការខ្វះខាតដូចជាជំនាន់មុនទៀតណាស់ ។

វណ្ណៈ៖ បាទ ។

លន់៖ ព្រោះជំនាន់មុនវាលំបាកណាស់ ហើយធ្វើហូបចុកមិនបានគ្រប់គ្រាន់អាហ្នឹងចឹង ចឹងហើយបានថា យើងសព្វថ្ងៃនេះល្អណាស់ យើងមានប្រាស្រ័យទាក់ទងគ្នារកស៊ីខ្វះខាតអី ស្រុកយើងចាយលុយ គេទិញយើង យើងទិញគេ កន្លែងណាយើងអាចសុំគ្នាហូបក៏បាន ។

វណ្ណៈ៖ បាទ ។

លន់៖ ហ្នឹងហើយយើងសម្រាប់អ្នកស្រុកស្រែយើងចឹង ខ្វះខាតយកដៃគ្នាគោយន្តក៏ដោយគោក៏ដោយយើងមានយកដៃគ្នាខ្លះ ។

វណ្ណៈ៖ ចឹងដូចថាក្នុងការទំនាក់ទំនងក្នុងគ្រួសារដូចពូចឹង ដូចថាឆ្នាំនេះពូប្រកបមុខរបរបង្កបង្កើនផលចឹង ដូចថាពូត្រូដាំអី ពូមានដែលពិភាក្សាជាមួយមីងថា យើងឆ្នាំនេះត្រូវដាំអីឆ្នាំក្រោយត្រូវដាំអីបែបហ្នឹងដែលមានការភិភាក្សាគ្នាទេ?

លន់៖ អាហ្នឹងមានពិភាក្សាគ្នាឲ្យបានដឹង ព្រោះទៅតាមអ្នកជំនួញនៅតាមតំបន់មួយៗ ដូចខាងខ្ញុំចឹងធ្វើស្រែ ចិញ្ចឹមគោ ហើយដាំដំណាំ ដំឡូងនិងសណ្តែកចឹង អាហ្នឹងត្រូវពិភាក្សាគ្នាហើយមានអង្គការមួយចំនួនគេចុះមក ថាយើងចង់អី រៀនដាំដំឡូង ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ គេចែកជាក្រុមៗគេឲ្យយើងចេះ អង្គការគេជួយទៀត អាហ្នឹងចឹង ។

វណ្ណៈ៖ បាទ ។

លន់៖ ហើយមានពិភាក្សាក្នុងគ្រួសារថែមទៀត យើងត្រូវដាំអីធ្វើអីចឹង យើងចង់បានដាំអីយើងធ្វើទៅ បញ្ជូនកូនទៅរៀនជាមួយគេ ម៉ែឪអ្នកចិញ្ចឹមហ្នឹង ចិញ្ចឹមជ្រូកចឹង រៀនចិញ្ចឹមជ្រូក ចង់ចិញ្ចឹមមាន់រៀនចិញ្ចឹមមាន់ អាហ្នឹងគេសុទ្ធតែមានពិភាក្សាគ្នាឲ្យជាយោបល់ ។

វណ្ណៈ៖ ចឹងគេបង្រៀនហ្នឹងគេមានយកលុយពីយើងទេ?

លន់៖ អត់ទេ មានតែឲ្យយើងថែម ។

វណ្ណៈ៖ ចឹងល្អដែរ?

លន់៖ បាទ ។

វណ្ណៈ៖ ចឹងពេលផលដំណាំដែលយើងធ្វើបានហ្នឹង តើយើងអាចទប់ទល់ហ្នឹងកម្លាំងថ្លៃដីថ្លៃអីប្រេងបានទេ?

លន់៖ ចេះរាល់សព្វថ្ងៃនេះ បញ្ហាទទួលស្គាល់រឿងស្រូវ ស្រុកខ្ញុំនេះមិនសូវប្រើដីទេ ពីរបីហិចតាអីនេះ ទើបតឡូវទេ មានប្រើដីទិញមួយបេគ្រាន់មកដាក់កន្លែងណាដែលមិនសូវល្អ បើចម្ការល្អពេក ។

វណ្ណៈ៖ បាទ ។

លន់៖	បើស្រូវយើងដាំ យើងព្រួសពីមុនមកយើងចាំងនិងចប់ធ្វើ ឥឡូវយើងមានលុយកាក់ហ្នឹង យើងបាញ់ថ្នាំអីខ្លះ យើងអាចរកសល់ ចំណីហូបហើយចំនិញលុយទៀត ។

វណ្ណៈ	ចឹងយើងអាចរស់បាន?

លន់៖	រស់ រស់បានដោយធូរស្រួល មិនខ្វាចទឹកលិចស្រួលណាស់ស្រុកនេះ ខ្ញុំធ្លាប់នៅភូមិត្រោយ “ង” ឃុំរក្សជ័យនេះរាប់ឆ្នាំតាំងពីកើតមកពីភូមិចាស់ដល់ភូមិថ្មី ទើបឥឡូវពុគេថាធ្វើផ្លូវថ្នល់ជាតិអីខ្ញុំមិនទាន់បានទៅជួបទេ តាំងពីកើតមកដល់ប៉ុណ្ណឹងអាយុ៥០ទៅ៦០ឆ្នាំហើយខ្ញុំមិនទាន់ស្គាល់ផ្លូវជាតិអីភូមិខ្ញុំទេណាស់ ទឹកលិចរាល់ឆ្នាំ ទៅមើលទៅវាលគោកប្រេះ ព្រែកហូរ តាមសេកសទន្លេដិះតែគោរាល់ថ្ងៃវាបិបាកណាស់ ។

វណ្ណៈ	បាទ ។

លន់៖	ហើយអុសសុទ្ធតែរែកបួនទៅប្រាំគីឡូបានៗអុសដុតហើយមើលបើអុសខ្ញុំនៅក្រោយផ្ទះនេះ ។

វណ្ណៈ	ចឹងកូនចៅអីលែងទៅស្រុកកំណើតវិញហើយ?

លន់៖	បាទ! នៅហ្នឹងហើយបើទៅៗលេងមានអី ។

វណ្ណៈ	និយាយទៅយើងនៅតាមជាយដែនហ្នឹងអាចជួយការពារព្រំដែនបានមួយចំនួនដែរ?

លន់៖	បាទ! ហើយខាងខ្ញុំក៏រៀបចំខ្ញុំខាងមេភូមិហ្នឹងនៅដីខាងនោះណាស់ នៅសល់ដីខាងនោះសុំឲ្យប្រជាជនរស់នៅច្រើនហើយមាន៦៧គ្រួសារជាប់ជើងភ្នំហ្នឹង នៅខាងនោះ ។

វណ្ណៈ	បាទ ។

លន់៖	ជិតដល់ភ្នំខាងនោះភ្នំ ។

វណ្ណៈ	ចឹងនៅក្នុងភូមិពូហ្នឹងមានប៉ះពាល់ដីធ្លីជាមួយក្រុមហ៊ុនណាទេ សព្វថ្ងៃហ្នឹង?

លន់៖	អត់មានទេ ខាងក្រុមហ៊ុនអត់មានទេ វាប៉ះតែខាងនោះទេ តែខាងសម្តេចនាយកហ្នឹងឲ្យនិសិត្សចុះមកចែកវាស់វែងអីហ្នឹងមិនមានបញ្ហាទេ អាហ្នឹងលើបញ្ហាយើងចេះរុករានកាប់ទន្រ្ទានធ្វើមិនល្អហ្នឹងណាស់ ធ្វើអីមិនកើតធ្វើស្រែធ្វើចម្ការទៅ ភូមិខ្ញុំមានប៉ុណ្ណឹងរឿងទាស់ទាញរឿងដីធ្លីគ្មានទេ ។

វណ្ណៈ	ចឹងធូរដែរ?

លន់៖	ធូរមិនពិបាកទេ តែខ្ញុំមេភូមិមិនពិបាកដោះស្រាយដែរ របស់ពីណាពីហ្នឹងធ្វើទៅ ។

វណ្ណៈ	បាទ ។

លន់៖	ពិតមែនតែមិនទាន់មានបណ្ណរឹងប្លង់អី មានត្រឹមប្លង់ភូមិឃុំហ្នឹង ខ្លះក៏មិនទាន់ធ្វើអីផង ។

វណ្ណៈ	ចឹងនៅក្នុងភូមិឃុំយើងហ្នឹង នៅត្រឹមស្រុកត្រឹមឃុំអីហ្នឹងអត់មានក្រុមហ៊ុនឬមួយរោងចក្រណាគេមកបង្កើតនៅហ្នឹងទេ?

លន់: អត់ទាន់មានទេ មានតែអង្គការនានាជួយបន្តិចបន្តួច គ្រាន់ជួយបង្ហាត់បង្រៀនឲ្យចេះដឹងអីបន្តិចបន្តួចខាងផ្នែកចិញ្ចឹមផ្នែកដាំចឹង ។

វណ្ណៈ: បាទ ។

លន់: ឲ្យស្គាល់ ។

វណ្ណៈ: ចឹងបើសិនជាមានដូចថារោងចក្រអីនៅក្បែរហ្នឹង យើងអាចជួយខាងផ្នែកជីវភាពបានច្រើនទៀតដែលអត់ បើសិនជាមានរោងចក្រចុះមក?

លន់: បើសិនជាមានរោងចក្រយើងអាចជួយបានខ្លះ ខាងខ្ញុំនេះអត់មាន និយាយរួមភូមិខ្ញុំកម្រមានអ្នកចេញទៅរកស៊ីក្រៅណាស់ ព្រោះយើងធ្វើស្រែចម្ការ ស្រែធ្វើមិនអស់ផង ហើយទៅរកអីណាទៀត ។

វណ្ណៈ: បាទ ។

លន់: បើទៅប្រទេសគេមកវិញទិញដីធ្វើស្រែដដែលហ្នឹង ។

វណ្ណៈ: ចឹងនៅក្នុងភូមិនេះមិនសូវមានចំណាកស្រុកទៅស្រុកគេអី ទៅស្រុកថៃអីទេ?

លន់: មិនសូវមានទេ មានអ្នកខ្លះខាតបន្តិចបន្តួចបីបួនប្រាំនាក់ បើថាឲ្យទៅទាំងហ្វូងគ្មានទេ ព្រោះមួយឆ្នាំៗខំតែធ្វើស្រូវ ។

វណ្ណៈ: បាទ ។

លន់: ស្រុកខ្ញុំយើងកុំលក់ ធ្វើមួយឆ្នាំហូបប្រាំឆ្នាំ តែយើងលក់ខ្លះខាតទិញប្រេងអីចឹង កូនចៅរៀនអីចឹងណាស់ មួយឆ្នាំរួចមួយឆ្នាំអើវាមិនមានទេ ដោះស្រាយរួមវាមិនពិបាករដ្ឋាភិបាលជួយជួយតែអ្នកអត់គ្នាទីទាល់ដៃជើង ទីទាល់កម្លាំងពលកម្ម គ្មានអត់ណាស់ ។

វណ្ណៈ: ចឹងខ្ញុំដូចជាអស់ហើយ ខ្ញុំបានសំណេះសំណាលជាមួយពូដូចជាយូរដែលហើយមួយម៉ោងជាងហើយ ខ្ញុំអរគុណពូច្រើនហើយ តើពូមានអីចង់បន្ថែមទៀតទេ ។

លន់: ខ្ញុំគ្មានអីទៀតទេ អស់ហើយ ។

វណ្ណៈ: ចឹងអរគុណពូច្រើន ។

លន់: បាទ ។

**ចប់**